ក

មាតិកា

I-ព្រះរាជឱង្ការលំយឹងព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៤-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧០ ស្តីពី ការផ្ទេរក្របខ័ណ្ឌ និង តម្លើងឋានន្តរស័ក្តិ ឯកឧត្តម អ៊ឹង សេរីវិសុទ្ធ ឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ទៅឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ៨៨២៣

១៤-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧១ ស្តីពី ការតម្លើងឋានៈស្មើ អគ្គនាយក ជូនឯកឧត្តម អ៊ុម រម្យណី នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នៃក្រសួងអប់រំ យុវជន និង កីឡា ៨៨២៤

១៦-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះសម្តេច ស៊ីសុវត្ថិ ជីវ័ន្តមុនីវង្ស និង ឯកឧត្តម ធេង ឧន ៨៨២៥

១៦-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកឧកញ៉ា,លោកជំទាវ និង អស់លោក ចំនួន ១៦ រូប ៨៨២៦

១៨-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧៥ ស្តីពី ការតែងតាំងលោកបណ្ឌិត ស សេរីវិចិត្រ ជា ឧកញ៉ា ៨៨២៧

១៨-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧៦ ស្តីពី ការតែងតាំងឯកឧត្តម ចំនួន ០២ រូប ជា ទីប្រឹក្សាសម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៨៨២៨

១៨-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ ក្រសួង មហាផ្ទៃ ចំនួន ០៨ រូប ៨៨២៩

១៨-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូននាយនគរបាលជាតិ ជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ២៧ រូប ៨៨៣០

១៨-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៧៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោក ឧត្តមសេនីយ៍ត្រី សម គារ៉ា នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៨៨៣២

II.រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៣-១១-២០០៩ -អនុក្រឹត្យលេខ ១៩៦ អនក្រ.បក ស្តីពី ការផ្តេរឥណទានថវិកា	៨៨៣៣
២៣-១១-២០០៩ -អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្តីពី ការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិ និង ផ្លូវរថភ្លើង នៃព្រះរាជាណាចក្រកម្ពុជា	៨៨៣៥
២៤-១១-២០០៩ -អនុក្រឹត្យលេខ ១៩៨ អនក្រ.បក ស្តីពី ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវក្ស ពន្ធនាគារ	៨៨៤១
២៤-១១-២០០៩ -អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជា តំបន់ប្រើប្រាស់ដោយចីរភាព	៨៨៤៤
២៤-១១-២០០៩ -អនុក្រឹត្យលេខ ២០០ អនក្រ.បក ស្តីពី លក្ខណៈ និង បែបបទ នៃការធ្វើដំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យាពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និង ការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា	៨៨៤៦
១៦-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	៨៨៥៨
១៧-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣១ អនក្រ.តត ស្តីពី ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិ អគ្គិសនីភាវូបនីយកម្មជនបទ នៃព្រះរាជាណាចក្រកម្ពុជា	៨៨៥៩
១៧-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣២ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស	៨៨៦២
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៨៨៧៨
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ	៨៨៧៩
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ	៨៨៨២
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	៨៨៨៣
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ	៨៨៨៦
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ	៨៨៨៨
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៣៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	៨៨៨៩
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៤០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	៨៨៩០
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៤១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ	៨៨៩១
១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៤២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	៨៨៩២

១៨-១១-២០០៩ -អនុក្រឹត្យលេខ ១៦៤៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៨៩៣

១៩-១១-២០០៩ -អនុក្រឹត្យលេខ ១៦៤៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៨៩៤

១៩-១១-២០០៩ -អនុក្រឹត្យលេខ ១៦៤៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៨៨៩៦

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម

០៦-១១-២០០៩ -ប្រកាសអន្តរក្រសួងលេខ ៩៩៤ សហវ.ប្រក ស្តីពី ការអនុវត្តន៍កិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈ ការគ្រប់គ្រងហានិភ័យ ៨៨៩៧

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-១១-២០០៩ -ប្រកាសលេខ ១០៩៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិនមីង អ៊ិនធើណេសិនណល គ្រុប បង្កើតរោងចក្រផលិតសម្បៅកបំពាក់ ៨៩០២

១៨-១១-២០០៩ -ប្រកាសលេខ ១០៩៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មីនម៉ាក (ខេមបូឌា) បង្កើតរោងចក្រផលិតសម្បៅកបំពាក់ ៨៩០៧

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៣-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៥០៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប្រ៊ីន ស៊ីបភីង អេជីនស៊ី (ខេមបូឌា) ខូ អិលធីឌី ៨៩១២

០៣-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៥០៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សូវ លីលីម គ្រុប ៨៩១៤

០៣-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៥០៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេមបូឌាន អេវីអេសិន ៨៩១៦

០៣-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៥០៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អិល & វ៉ាយ អ៊ិនធើរ-ត្រេដ (ខេមបូឌា) ៨៩១៨

០៣-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៥១០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស្ព័ត សូសល អីហ៊ែរ (អេស អេស អេ) ៨៩២០

០៣-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៥១១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន បេស ម៉ាស់រូម (ខេមបូឌា) ខូ អិលធីឌី ៨៩២២

០៤-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៥១៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន កំពង់សោម អ៊ិនធើប្រ្តេធីត អេសអ៊ីហ្សេត ៨៩២៤

០៤-០២-២០០៩	-លិខិតបញ្ជាក់លេខ ០៥២២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ីន ពិទ័ន្ធ ខនស្ត្រាក់សិន	៨៩២៧
០៤-០២-២០០៩	-លិខិតបញ្ជាក់លេខ ០៥៣៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន មរតក អ៊ិនធើណេសិនណល គ្រុប	៨៩២៩
០៥-០២-២០០៩	-លិខិតបញ្ជាក់លេខ ០៥៤៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន គូម៉ាណា ខូ អិលធីឌី	៨៩៣១
០៥-០២-២០០៩	-លិខិតបញ្ជាក់លេខ ០៥៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ.អេ (ខេមបូឌា) ត្រេនស្ផ័តថេសិន ខូ អិលធីឌី	៨៩៣៣

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខិតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្ជបូរណាសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិក: មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិក: ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភ: ឆ្នាំ ២០០០ ស្តីពីលក្ខន្តិក: ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ក្រោសំបង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរក្របខ័ណ្ឌ និងដំឡើងឋានន្តរស័ក្តិ ឯកឧត្តម **អ៊ុច សេរីវិសុទ្ធ** ឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ទៅឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជកររ
នរោត្តម សីហមុនី

ត្រូវ.ចម្លង.ប្រទេ

លេខ:១៧៦ ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩
អគ្គលេខាធិការរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧៦ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោតាស កម្ពុជឯករាជ្ជបូរណាសន្តិ សុតមច្ចលា សីរីវិបុលា
ខេមរាស្ថីពីរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានៈស្មើ **អគ្គនាយក** ជូនឯកឧត្តម **អ៊ុម រម្យណី** នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នៃក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆកររ
នរោត្តម សីហមុនី

ចម្លងលេខ:៤៩៧ ច.ល
ដើម្បីប្រគល់ជូនចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩
រដ្ឋលេខាធិការដ្ឋានអាវុធាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ជិនកេន

ថ្ងៃ ល. ០៩ ១១. ២០០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧៤ យើង

ព្រះតរុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតូតខត្តិយា ខេមរាវដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស តម្ពុជឯករាជវដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងតម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ**

ចំពោះ

សម្តេច **ស៊ីសុវត្ថិ ជីវ៉ន់មុនីរ៉ក្ស**
ឯកឧត្តម **ឧេព ចន**

៣រល.០៩១១.១០៩៣ **ព្រះហស្តលេខា និងព្រះរាជលញ្ឆការ**
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩

លេខ:១០០៦ច.ល
ជើម្បីមមួងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ២០០៩
រាជឡេខាធិការរងទាប់រដ្ឋាភិបាល

ឃុន ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧៣

យើង

ព្រះតេជគុណព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហានភូមិន្ទាភិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារស្ត្រ ពុទ្ធិន្ទ្រាធរមហាត្ឋ្យក្ត
ខេមរាជនា សម្ភហោភាស តម្ពុជឯករាជរដ្ឋប្បវណសន្តិ សុតមន្តលា សីរីតិប្ញលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងតម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រតម្ពុជា ថ្នាក់ មហាសេរីតង្ហាន៍ ចំពោះ :

១- ឯកឧត្តម ង៉ាន់ ស្បឿន	២- ឯកឧត្តម ច័ន្ទ សំអាន
៣- ឧត្តមសេនីយ៍ត្រី គន្ធ តារាឥណ្ឌ	៤- លោក ង៉ាន់ ឆារស៍
៥- លោក ឈួត បណ្ឌិត	៦- លោក លី ឃាង
៧- លោកវរសេនីយ៍ទោ សួស សុខដារ៉ា	

ខ-គ្រឿងឥស្សរិយយស សុភក្តារា ថ្នាក់ មហាសេរីតង្ហាន៍ ចំពោះ :

១- ឯកឧត្តមឧកញ៉ា ហោង ស្បៅ	២- ឯកឧត្តម ហាក់ សុខមករា
៣- ឯកឧត្តម ឡូ នីម	៤- លោកជំទាវ ស្បៅម ជូ

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីតង្ហាន៍ ចំពោះ :

១- ឯកឧត្តម ហ៊ឹត សុភណ្ឌ	២- លោកឧកញ៉ា លី សាយ ឃាង
៣- លោក គីម ពិសិដ្ឋ	៤- ព្រះសាសនៈមុនី ជេត ឥន
៥- លោកឧកញ៉ា ឡាត ង៉ាន់	

ព្រះហស្តលេខា និងព្រះរាជលញ្ឆកររ
នរោត្តម សីហមុនី

៣រ៧.០៩១១.២០៩៤

លេខ:១០០៧ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ត្រឹមត្រូវបញ្ជូនចេក
រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៩
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ឥនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧៤

យើង

ព្រះតរុណោព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រតូតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា

សីរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកបណ្ឌិត ស សើវិចិត្រ

ជា

ឧកញ៉ា

៣៤៧.០៩១១.១០៩៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩

លេខ:១០០៤ ច.ល
ជើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩
រដ្ឋលេខាធិការរាងរាជរដ្ឋាភិបាល

ឃុន ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧៦ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា ត្រកូតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោតាស តម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងតម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាបន័ជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

ត្រាសំបង្គាប់

មាត្រា១ : ត្រូវបានតែងតាំង :

១-ឯកឧត្តម វ័ណ្ណ មុនី ជាទីប្រឹក្សាសម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២-ឯកឧត្តម មាស សំណាង ជាទីប្រឹក្សាសម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ**អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា២ : សម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន**ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆកអរ
នរោត្តម សីហមុនី

ត្រឹមត្រូវ
ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩
រដ្ឋលេខាធិការក្រសួងរាជរដ្ឋាភិបាល
ជិន ភេទន

ត្រូវនឹង ៣រស.០៩១១.១០៩៧ លេខ:១០០៥ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមីជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជាអ្នស្ត ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោតាស កម្ពុជឯករាជ្យបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ក្រោសរបង្ហាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

១-លោកវរសេនីយ៍ឯក	**កើត សារុន**	អត្តលេខ ០៦៦៣
២-លោកវរសេនីយ៍ឯក	**កើត សំផន**	អត្តលេខ ០៩៩១
៣-លោកវរសេនីយ៍ឯក	**ហេង ប៊ុន**	អត្តលេខ ០៩៩៨
៤-លោកវរសេនីយ៍ឯក	**កែវ ចន្ថា**	អត្តលេខ ០៥៨៧
៥-លោកវរសេនីយ៍ឯក	**ចួន ផ្ដួល**	អត្តលេខ ០៧៨៨
៦-លោកវរសេនីយ៍ឯក	**យស់ ផន**	អត្តលេខ ០៥៨៩
៧-លោកវរសេនីយ៍ឯក	**សេង ក្រែ**	អត្តលេខ ២០៤៦៣
៨-លោកវរសេនីយ៍ឯក	**ម៉ុក ចណ្ណា**	អត្តលេខ ០៤៧៧៧ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជការ
នរោត្តម សីហមុនី

ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ត្រឹមត្រូវចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការដ្ឋានរដ្ឋាភិបាល

ឈឹម ចិនកេន

ថ្ងៃ.០៩.១១.២០៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជារាស្ត្រ ពុទ្ធិង្ករោធរាមហាក្សត្រ
ខេមរាជនា សមូហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

ក-ថ្នាក់ឧត្តមសេនីយ៍ឯក :

១-លោកឧត្តមសេនីយ៍ទោ **ថោង ឈឹម**	អត្តលេខ	០០៤៨
២-លោកឧត្តមសេនីយ៍ទោ **ចាន់ គីមសេង**	អត្តលេខ	០១១៤
៣-លោកឧត្តមសេនីយ៍ទោ **ម៉ក់ ជីតូ**	អត្តលេខ	០៧៧១

ខ-ថ្នាក់ឧត្តមសេនីយ៍ឆ្មោ :

១-លោកឧត្តមសេនីយ៍ត្រី **នួន បូផល**	អត្តលេខ	០២០៥
២-លោកឧត្តមសេនីយ៍ត្រី **ជុំ សាភុឌ្ឍ**	អត្តលេខ	០៧៧៥
៣- លោកឧត្តមសេនីយ៍ត្រី **ជា ពៅ**	អត្តលេខ	០២២០២
៤- លោកឧត្តមសេនីយ៍ត្រី **សេង សិរីបុត្រ**	អត្តលេខ	០២២០៥
៥- លោកឧត្តមសេនីយ៍ត្រី **រុន រ័ត្នវាសនា**	អត្តលេខ	៥៦០៣៥

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL *

៦- លោកឧត្តមសេនីយ៍ត្រី **ឡាយ ទីសា**	អត្តលេខ	៥៤៦៩៥
៧- លោកឧត្តមសេនីយ៍ត្រី **ព្រំ ធា**	អត្តលេខ	០៣៧៨
៨- លោកឧត្តមសេនីយ៍ត្រី **គឹម សាម៉ន**	អត្តលេខ	០៦៨៣
៩- លោកឧត្តមសេនីយ៍ត្រី **ពិន ពិសិដ្ឋ**	អត្តលេខ	០៣៦៥
១០- លោកឧត្តមសេនីយ៍ត្រី **អៀក ខែម**	អត្តលេខ	០៤២២
១១- លោកឧត្តមសេនីយ៍ត្រី **អ៊ិន ឃូរ៉ា**	អត្តលេខ	០២១០
១២- លោកឧត្តមសេនីយ៍ត្រី **មៅញ កំសាន្ត**	អត្តលេខ	០១២១
១៣- លោកឧត្តមសេនីយ៍ត្រី **ម៉ម ស្រ៊ីមទណ្ណា**	អត្តលេខ	០៦៩៥
១៤- លោកឧត្តមសេនីយ៍ត្រី **គូច ប៊ុនលាត**	អត្តលេខ	០៦០៨

គ-ថ្នាក់ឧត្តមសេនីយ៍ត្រី :

១-លោកវរសេនីយ៍ឯក **អ៊ូន សាបូរ**	អត្តលេខ	០២៥០
២-លោកវរសេនីយ៍ឯក **រស់ សុខា**	អត្តលេខ	០១៣២៩
៣-លោកវរសេនីយ៍ឯក **យ៉ឹម ទីរ:**	អត្តលេខ	០៨៨៨
៤-លោកវរសេនីយ៍ឯក **នង សុផល**	អត្តលេខ	០៧៤២
៥-លោកវរសេនីយ៍ឯក **ទ៉ាន់ ម៉ុន**	អត្តលេខ	០៨២៨
៦-លោកវរសេនីយ៍ឯក **ប្រ៊ីង ជាទណ្ណ៉ា**	អត្តលេខ	០១៩៩
៧-លោកវរសេនីយ៍ឯក **នូន គឹមសូរ**	អត្តលេខ	០១៩៣
៨-លោកវរសេនីយ៍ឯក **គិន ឡាយ**	អត្តលេខ	០៦២១
៩- លោកវរសេនីយ៍ឯក **ឃី សាម៉ៀន**	អត្តលេខ	០៦៨០
១០-លោកវរសេនីយ៍ឯក **យ៉ឹម ស៊ីមុន្នី**	អត្តលេខ	០៣៦២៧ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រស.០៩១១.១០៩៩ **នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩

លេខ:១០០៨ ច.ល

ជៃម្បីមម្ចងចែក

ភ្នំពេញ, ថ្ងៃទី ៨៤ ខែ វិច្ឆិកា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រកូតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីចិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឆោ** ជូនលោកឧត្តមសេនីយ៍ត្រី **សម តារា** អត្តលេខ ០៣៦៧ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥១១.១១០០

លេខ:១០០៧ ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៩
រដ្ឋលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ឆ្នាស ឌិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៩៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក , ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៩០០ លានរៀល (ប្រាំបួនរយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) របស់ ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន សម្រាប់ចំណាយដំណើរការបន្ត រហូតដល់ដំណាច់ឆ្នាំ ២០០៩ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៩៩. អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង

នៃព្រះរាជាណាចក្រកម្ពុជា

* * * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់ការគ្រប់គ្រង និងការប្រើប្រាស់ដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង ឱ្យសមស្របតាមការអភិវឌ្ឍ និងការរីកចម្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២.-

អនុក្រឹត្យនេះមានគោលបំណង៖

- លុបបំបាត់បាតុភាពទន្ទ្រានយកដីចំណីទៅធ្វើការសាងសង់សំណង់ ឬដាំដំណាំផ្សេងៗ
- ទប់ស្កាត់ឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍និងរក្សាសណ្តាប់ធ្នាប់សង្គមដែលតែងកើតមាននៅតាមបណ្តាញផ្លូវ
- កាត់បន្ថយឧបសគ្គនានាដែលរាំងស្ទះដល់ការអភិវឌ្ឍផ្លូវ
- កាត់បន្ថយរាល់ការចំណាយរបស់រដ្ឋលើការដោះស្រាយផលប៉ះពាល់ផ្ទះសម្បែងប្រជាពលរដ្ឋដែលតាំងនៅតាមបណ្តាញផ្លូវ
- បង្កលក្ខណៈងាយស្រួលដល់សមត្ថកិច្ចពាក់ព័ន្ធក្នុងការផ្តល់ភាពស្របច្បាប់ដល់ប្រជាពលរដ្ឋដែលមានកម្មសិទ្ធិនៅតាមបណ្តាញផ្លូវ
- ធានាការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៣.-

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់ទៅលើផ្លូវជាតិមានលេខ១(មួយ)ខ្ទង់ ផ្លូវជាតិមានលេខ២(ពីរ)ខ្ទង់ ព្រមទាំងផ្លូវរថភ្លើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ។

អនុក្រឹត្យនេះ មិនមានវិសាលភាពគ្របដណ្តប់ទៅលើផ្លូវអភិវឌ្ឍទាំងឡាយនៅតាមបណ្តោយព្រំដែនដែលមិនមែនជាផ្លូវជាតិ ផ្លូវជាតិក្នុងដែនបម្រុងសត្វព្រៃនិងឧទ្យានជាតិ ផ្លូវជាតិក្នុងដែនបម្រុងរុក្ខា ផ្លូវលំជនបទ ផ្លូវជាតិអមប្រឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងនិងទទួលខុសត្រូវដោយក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹកនិងឧតុនិយម និងផ្លូវជាតិផ្សេងៗទៀតដែលសាងសង់ដោយឃុំ សង្កាត់ សហគមន៍ និងប្រជាពលរដ្ឋ ។

មាត្រា៤.-

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ៖

- ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង សំដៅដល់ចម្រៀកដីសងខាងអ័ក្សនៃផ្លូវជាតិនិងផ្លូវរថភ្លើង ដែលត្រូវបានអភិវឌ្ឍឬនឹងត្រូវអភិវឌ្ឍ ហើយត្រូវបានដាក់ឱ្យនៅក្រោមការគ្រប់គ្រងនិងការទទួលខុសត្រូវទាំងស្រុងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដោយបម្រុងទុកស្របតាមបទដ្ឋានបច្ចេកទេស ដែលមានប្រវែងពីអ័ក្សទៅតាមប្រភេទផ្លូវដូចមានចែងក្នុងមាត្រា៨និងមាត្រា៩នៃអនុក្រឹត្យនេះ

- ផ្លូវជាតិ ហៅកាត់ថា "ផ្លូវ" សំដៅដល់ទំហំផ្លូវទាំងមូល ដែលរួមមានទ្រូងផ្លូវ រួមជាមួយជាយផ្លូវ ឬ ចិញ្ចើមផ្លូវ

- ផ្លូវរថភ្លើង សំដៅដល់ផ្លូវដែលកើតឡើងដោយការសាងសង់សម្រាប់ឱ្យរថភ្លើងធ្វើចរាចរណ៍ ដឹកជញ្ជូនគ្រប់ប្រភេទ រួមទាំងសំណង់សិល្បការ្យ និងបរិក្ខារផ្លូវរថភ្លើង

- ទ្រូងផ្លូវ សំដៅដល់ផ្នែកមួយនៃផ្លូវទុកសម្រាប់យានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍

- ជាយផ្លូវ សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវដែលនៅក្រៅទីប្រជុំជន ហើយអាចចតយានជំនិះ នៅទីនោះបានក្នុងករណីចាំបាច់

- ចិញ្ចើមផ្លូវ សំដៅដល់ជាយផ្លូវនៅក្នុងទីប្រជុំជនដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ប៉ុន្តែមិនអាចចតយានជំនិះនៅទីនោះបានទេ

- ផ្លូវជាតិ សំដៅដល់ៈ

  ១- ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញ ឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស ។

  ២- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត ។

  ៣- ផ្លូវភ្ជាប់ចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវជាតិ ។

  ៤- ផ្លូវបំបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយ ។

  ៥- ផ្លូវភ្ជាប់ចេញពីផ្លូវជាតិទៅកាន់តំបន់សំខាន់ៗជាអាទិ៍ កំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋានតំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរ ច្រកទ្វារព្រំដែន និងតំបន់មានសក្តានុពលសេដ្ឋកិច្ចផ្សេងៗទៀត ។

  ៦- ផ្លូវសំខាន់ៗរបស់ជាតិ មានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ។

ផ្លូវជាតិ ត្រូវបានបែងចែកជា ២(ពីរ) កម្រិតៈ

- ផ្លូវជាតិកម្រិត ១ សំដៅដល់ផ្លូវជាតិ ដែលតាងដោយលេខ ១(មួយ) ខ្ទង់
- ផ្លូវជាតិកម្រិត ២ សំដៅដល់ផ្លូវជាតិ ដែលតាងដោយលេខ ២(ពីរ) ខ្ទង់ ។

- ផ្លូវតំបន់ សំដៅដល់បណ្តាផ្លូវជាតិដែលតភ្ជាប់ជាមួយផ្លូវប្រទេសជិតខាងស្ថិតក្នុងតំបន់ និងត្រូវបានកំណត់ជាលក្ខណៈអន្តរជាតិ

- ផ្លូវសាធារណៈ សំដៅដល់ផ្លូវសម្រាប់បើកឱ្យធ្វើចរាចរណ៍ទូទៅជាសាធារណៈ

- ផ្លូវឯកជន សំដៅដល់ផ្លូវកសាងដោយឯកជនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈ ហើយដែលបានសាងសង់ ឬជួសជុលដោយឯកជនតាមកិច្ចសន្យាជាមួយរដ្ឋ

- សំណង់សិល្បការ្យ សំដៅដល់ ស្ពាន លូ ប្រព័ន្ធបង្ហូរទឹក អាងស្តុកទឹកបម្រើឱ្យផ្លូវជាតិ ផ្លូវរថភ្លើង និងសំណង់រូបវន្តផ្សេងៗទៀតដែលផ្តល់នូវសុវត្ថិភាព និងប្រសិទ្ធភាព ស្ថិរភាពនៃផ្លូវជាតិ និងផ្លូវរថភ្លើង

- បរិក្ខារផ្លូវជាតិ ផ្លូវរថភ្លើង សំដៅដល់ របង របាំងការពារ ផ្ទាំង និងស្លាកសញ្ញា ក្រឹងប៉ូឌ៍ ភ្លើងចរាចរ កន្លែងសម្រាក ទីចំណត ស្ថានីយរថភ្លើង ព្រមទាំងសម្ភារៈនិងសំណង់ផ្សេងៗទៀត ដែលបានសាងសង់ឡើងលើ ផ្លូវជាតិនិងផ្លូវរថភ្លើង ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ ឬបម្រើផលប្រយោជន៍ ផ្លូវជាតិ និងផ្លូវរថភ្លើង

- ការអភិវឌ្ឍផ្លូវជាតិ ផ្លូវរថភ្លើង សំដៅដល់ការស្ថាបនា ការស្តារឡើងវិញ និងការកែលម្អផ្លូវជាតិ ផ្លូវរថភ្លើង ដោយមិនរាប់បញ្ចូលការថែទាំផ្លូវជាតិនិងផ្លូវរថភ្លើងឡើយ

- ទីប្រជុំជន សំដៅដល់ទីកន្លែងដែលមានអគារឬគេហដ្ឋានសង់ជិត១ភ្លា ហើយផ្លូវចេញឬចូលនៅទីនោះមានដាក់ផ្លាកសញ្ញាឈ្មោះទីប្រជុំជន។

ជំពូកទី២
ការគ្រប់គ្រងនិងប្រើប្រាស់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង

មាត្រា៥.-

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីចំណីផ្លូវជាតិ និងផ្លូវរថភ្លើង ក្នុងការធ្វើផែនការ ការសិក្សាគម្រោងបង្អភិវឌ្ឍផ្លូវជាតិនិងផ្លូវរថភ្លើង ឬផ្តល់សេវាកម្មផ្សេងៗទៀតដែលពាក់ព័ន្ធនឹងផ្លូវជាតិនិងផ្លូវរថភ្លើង ដើម្បីបម្រើផលប្រយោជន៍អ្នកប្រើប្រាស់ផ្លូវជាតិ និងផ្លូវរថភ្លើងឱ្យមានប្រសិទ្ធភាពល្អ។

មាត្រា៦.-

ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងការគ្រប់គ្រងដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង ដោយផ្អែកលើគោលការណ៍ច្បាប់ជាធរមាន។

ជំពូកទី៣
ការកំណត់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង
សម្រាប់បម្រើការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

មាត្រា៧.-

ដីចំណីនៅតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង គឺជាសម្បត្តិសាធារណៈរបស់រដ្ឋ ស្របតាមមាត្រា១៥ នៃច្បាប់ភូមិបាល។

មាត្រា៨.-

ដីចំណីផ្លូវ ត្រូវបានកំណត់សម្រាប់បម្រើការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចតទៅ៖

- ផ្លូវជាតិកម្រិត១ : តាងដោយលេខ១(មួយ)ខ្ទង់ ដីចំណីផ្លូវមានប្រវែង៣០(សាមសិប)ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ

- ផ្លូវជាតិកម្រិត២ : តាងដោយលេខ២(ពីរ)ខ្ទង់ ដីចំណីផ្លូវមានប្រវែង២៥(ម្ភៃប្រាំ)ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ។

ចំពោះដីចំណីផ្លូវជាតិនៃប្រភេទទាំង២(ពីរ)ខាងលើដែលឆ្លងកាត់រាជធានីឬក្រុងនៃខេត្តឬទីប្រជុំជន និងមិនកំណត់ដោយឡែកអំពីដីចំណីផ្លូវជាតិរបស់រាជធានី និងក្រុងនៃខេត្ត ឬទីប្រជុំជន។

មាត្រា៩.-

ដីចំណីផ្លូវរថភ្លើង ត្រូវបានកំណត់សម្រាប់បម្រើការអភិវឌ្ឍនិវស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- ដីចំណីផ្លូវរថភ្លើងក្រៅរាជធានី ក្រុង និងទីប្រជុំជន ត្រូវមានប្រវែង៣០(សាមសិប)ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ

- ដីចំណីផ្លូវរថភ្លើងដែលស្ថិតនៅក្នុងតំបន់ព្រៃភ្នំ ដែលមានថ្មរមៀលធ្លាក់ឬតំបន់ព្រៃខ្ពស់ ត្រូវមានប្រវែង១០០(មួយរយ)ម៉ែត្រពីសងខាងអ័ក្សផ្លូវ

- ដោយឡែកចំពោះដីបរិវេណស្ថានីយ៍រថភ្លើង ត្រូវអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

ចំពោះដីចំណីផ្លូវរថភ្លើង ដែលឆ្លងកាត់រាជធានីឬក្រុងនៃខេត្តឬទីប្រជុំជន នឹងមានកំណត់ដោយឡែកអំពីដី ចំណីផ្លូវរថភ្លើងរបស់រាជធានី និងក្រុងនៃខេត្ត ឬទីប្រជុំជន ។

មាត្រា១០.-

ការកំណត់ដីចំណីផ្លូវខាងលើត្រូវធ្វើឡើងតែម្តងគត់ ទោះបីត្រូវអភិវឌ្ឍផ្លូវថែមទៀតក៏ដោយ ការកំណត់ដីចំណីផ្លូវត្រូវរក្សានៅដដែល។

មាត្រា១១.-

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ មិនត្រូវអនុញ្ញាតឱ្យសាងសង់សំណង់ ការដាំដំណាំផ្សេងៗ នៅតាមដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើងឡើយ។

ការដាំដុះដំណាំមួយចំនួនមានលក្ខណៈអាស្រ័យផល ត្រូវមានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលនិងត្រូវមានកិច្ចសន្យាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ពេលត្រូវការអភិវឌ្ឍផ្លូវរដ្ឋមិនទទួលខុសត្រូវទូទាត់សំណងឡើយ។

មាត្រា១២.-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវចេញប្រកាសឬសេចក្តីណែនាំ ដើម្បីកំណត់ការប្រើប្រាស់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង សម្រាប់ជាប្រយោជន៍សាធារណៈនិងឯកជន ជាអាទិ៍ ការជីកកប់បណ្តាញ ខ្សែកាបអ៊ុបទិក បំពង់ទឹកស្អាត ការបោះបង្គោលអគ្គិសនី ការបោះបង្គោលអ៊ុបទិក ការបោះបង្គោលផ្សាយពាណិជ្ជកម្ម និងការប្រើប្រាស់ផ្សេងៗទៀត ទាក់ទងនឹងដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង។

ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវធ្វើការសិក្សាដើម្បីដាក់តាំងផ្ទាំងរូបភាព ស្តីពីការកំណត់ដីចំណីផ្លូវនៅតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង ជំនួសការបោះបង្គោលដីចំណីផ្លូវ។

ជំពូកទី៤

បទប្បញ្ញត្តិដោយឡែក

មាត្រា១៣.-

រដ្ឋធ្វើការទូទាត់សំណង ដោយអនុលោមតាមគោលនយោបាយនៃការតាំងលំនៅឡើងវិញតាមមាត្រា១៤៨នៃច្បាប់ភូមិបាល ចំពោះកម្មសិទ្ធិករស្របច្បាប់លើក្បាលដីដែលត្រូវប្រើប្រាស់កំណត់ជាដី[illegible] មានចែងក្នុងមាត្រា៨និង៩នៃអនុក្រឹត្យនេះ សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ការដែលបានកំណត់មុនអនុក្រឹត្យនេះ ព្រមទាំងស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

មាត្រា១៤.-

ការទូទាត់ផលប៉ះពាល់ចំពោះដីដែលបានកាន់កាប់ស្របច្បាប់ ដំណាំផ្សេងៗ ព្រមទាំងរបងនិងសំណង់ ទាំងឡាយ ដូចជា ទំនប់ទឹក ប្រឡាយទឹក ដីស្រែ ដែលបានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិនៃច្បាប់ ត្រូវ កំណត់ដោយរាជរដ្ឋាភិបាល ។

ជំពូកទី៥

ទោសប្បញ្ញត្តិ

មាត្រា១៥.-

រាល់ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ដែលមានចែងក្នុងមាត្រា៨និងមាត្រា៩នៃ អនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ជំពូកទី៦

អវសានប្បញ្ញត្តិ

មាត្រា១៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៧.-

រដ្ឋអន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋបន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង សាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩

នាយកឋ្លៃនន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.១៨៧...អ.ន.ស្តេ.ប៧

អនុក្រឹត្យ

ស្តីពី

ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុវត្តពន្ធនាគារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១:-

ត្រូវបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុវត្តពន្ធនាគារ សរសេរកាត់ "ម.ប.វ.អ.ព" ចំណុះបណ្ឌិត្យសភានគរបាលកម្ពុជា ។

មាត្រា២:-

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុវត្តពន្ធនាគារមានទំនាក់ទំនងស្មើនាយកដ្ឋាន ។ មជ្ឈមណ្ឌលនេះដឹកនាំដោយនាយក មួយរូប និង នាយករងមួយចំនួន ជាជំនួយ តាមការចាំបាច់ ។

មាត្រា៣:-

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ មានតួនាទីជាសេនាធិការជូនបណ្ឌិត្យសភានគរបាលកម្ពុជា លើការងារបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ កម្រិតមធ្យម (បរិញ្ញាបត្រវង) និងធ្វើវិក្រឹតការ សុក្រឹតការជំនាញឯកទេស ជូនមន្ត្រីអនុរក្ស និង ថ្នាក់ដឹកនាំពន្ធនាគារគ្រប់កម្រិត ។

បណ្ឌិត្យសភានគរបាលកម្ពុជា ត្រូវសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារក្នុងការរៀបចំកម្មវិធីសិក្សាកម្រិតមធ្យមវិជ្ជាជីវៈអនុរក្សពន្ធនាគារ ដោយមានការឯកភាពពី ក្រសួងមហាផ្ទៃ និង មានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា៤:-

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា កម្រិតមធ្យម(បរិញ្ញាបត្រវង)វិជ្ជាជីវៈអនុរក្សពន្ធនាគារ និង ទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រ បរិញ្ញាបត្រវង តាមមុខជំនាញឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះ នឹងចុះហត្ថលេខាដោយ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា៥:-

លក្ខខណ្ឌនៃការជ្រើសរើសសិស្ស និស្សិត ឱ្យចូលរៀន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ដោយអនុលោមទៅតាមបទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា៦:-

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារមានភារកិច្ច ដូចតទៅ :

- សហការជាមួយអង្គភាពពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្នុងការរៀបចំផែនការបណ្តុះបណ្តាល និង កម្មវិធី វិក្រឹតការ សុក្រឹតការជំនាញឯកទេស ជូនមន្ត្រីអនុរក្ស និង ថ្នាក់ដឹកនាំពន្ធនាគារគ្រប់ កម្រិត
- សិក្សាស្រាវជ្រាវធ្វើទំនើបភាវូបនីយកម្មខ្លឹមសារបង្ហាត់បង្រៀន កម្មវិធីសិក្សា និង កម្មសិក្សាប្រតិបត្តិ
- ចាត់វិធានការអនុវត្តផែនការបណ្តុះបណ្តាល តាមកម្មវិធីរបស់ បណ្ឌិត្យសភានគរបាលកម្ពុជា និង ក្រសួងមហាផ្ទៃ
- លើកគម្រោងផែនការថវិកា សម្ភារៈ របស់មជ្ឈមណ្ឌល
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដំណើរការសិក្សា តាមការកំណត់របស់ បណ្ឌិត្យសភានគរបាលកម្ពុជា និង ក្រសួងមហាផ្ទៃ
- បូកសរុបលទ្ធផលការងារ និងធ្វើរបាយការណ៍ជូនបណ្ឌិត្យសភានគរបាលកម្ពុជា
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់លើប្រគល់ឱ្យ ។

មាត្រា៧:-

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច អង្គភាពចំណុះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

មាត្រា៨:-

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៩:-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និង ស្ថាប័ន ដែលមានការពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ៧ ឆ្នាំ ២០០៩

នាយកដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៩
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥៥. រកត/ក.ប

អនុក្រឹត្យ

ស្តីពី

ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ
ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រ ម ច

មាត្រាទ: –

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃបឹងពែរ លើផ្ទៃដីទំហំ **៧.២៨៩ហិកតា (ប្រាំពីរពាន់ ពីររយ ប៉ែតសិបប្រាំបួន ហិកតា)** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកស្ទោង ខេត្តកំពង់ធំ សម្រាប់ផ្តល់ជូន

ក្រុមហ៊ុន C.R.C.K.2 APHIVATH CAOUT CHOUC CO.,LTD ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដាំដំណាំកៅស៊ូ ដែលមាននិយាមកា កំណត់ក្នុងផែនទីភ្ជាប់មកជាមួយ ។

មាត្រា២: -

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣៤ ខែ ៨ឬ៣ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០០.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

លក្ខខណ្ឌនិងបែបបទនៃការធ្វើដំណើរ ការជ្រើសរើស ការអប់រំ ការពង្រាវពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកាតព្វកិច្ចយោធា
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការងារ[illegible]របស់ក្រសួងការពារជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩

សម្រួច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខខណ្ឌ និងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា។

មាត្រា២.-

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ ៖

- ការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ
- ចូលរួមកែទម្រង់វិស័យកងទ័ព
- ពង្រឹងមូលដ្ឋានគ្រឹះនៃប្រភពកសាងកម្លាំងសម្រាប់វិស័យការពារជាតិ និងការអភិវឌ្ឍកាយសម្បទា ដែលជាតម្រូវការរបស់ប្រទេសជាតិ
- បណ្តុះបណ្តាលជំនាញការពារជាតិ។

មាត្រា៣.-

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ លើប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី១៨ (ដប់ប្រាំបី) ឆ្នាំ ដល់៣០ (សាមសិប) ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការបំពេញកាតព្វកិច្ចយោធារបស់ប្រជាពលរដ្ឋខ្មែរ ជាស្ត្រីភេទគ្រប់រូប ត្រូវផ្អែកតាមការស្ម័គ្រចិត្ត។

មាត្រា៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលប្រើក្នុងអនុក្រឹត្យនេះ សំដៅដល់ប្រជាពលរដ្ឋខ្មែរជាជនស៊ីវិលធម្មតា កម្មករ និយោជិត និយោជក សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល និងប្រជាពលរដ្ឋខ្មែរដែលមានសញ្ជាតិពីរ ហើយរស់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២

សមត្ថកិច្ចនិងយន្តការ

ផ្នែកទី១

គណៈកម្មាធិការជាតិកាតព្វកិច្ចយោធា

មាត្រា៥.-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិកាតព្វកិច្ចយោធា ហៅកាត់ថា **គ.ជ.ក.** ដែលមានសមាសភាពដូចតទៅ ៖

- រដ្ឋមន្ត្រីក្រសួងការពារជាតិ	ប្រធាន
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋលេខាធិការមួយរូប	អនុប្រធាន
- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬរដ្ឋលេខាធិការមួយរូប	សមាជិក
- រដ្ឋមន្ត្រីក្រសួងផែនការ ឬរដ្ឋលេខាធិការមួយរូប	សមាជិក
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬរដ្ឋលេខាធិការមួយរូប	សមាជិក
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬរដ្ឋលេខាធិការមួយរូប	សមាជិក
- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬរដ្ឋលេខាធិការមួយរូប	សមាជិក
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬរដ្ឋលេខាធិការមួយរូប	សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ	សមាជិក
- អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ	សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
- នាយក នាយកដ្ឋានបុគ្គលិកនៃក្រសួងការពារជាតិ	លេខាធិការ។

សមាសភាពជាក់ស្តែងនៃ **គ.ជ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៦.-

គ.ជ.ក. មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយជាតិកាតព្វកិច្ចយោធា
- អនុវត្តអនុក្រឹត្យស្តីពីចំនួនប្រជាពលរដ្ឋ និងលក្ខខណ្ឌទាំងឡាយ ក្នុងការចូលបំពេញកាតព្វកិច្ចយោធាសម្រាប់វគ្គនីមួយៗរៀងរាល់ឆ្នាំតាមសំណើរបស់ក្រសួងការពារជាតិនិងលិខិតបទដ្ឋានទាក់ទងនឹងកាតព្វកិច្ចយោធា
- រៀបចំទម្រង់បែបបទគំរូ ខ្លឹមសារសេចក្តីសម្រេច សេចក្តីណែនាំ និងវិធាននានាក្នុងដំណើរការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា
- ដឹកនាំ និងត្រួតពិនិត្យដំណើរការនៃការអនុវត្តកាតព្វកិច្ចយោធា
- តែងតាំងសមាសភាពគណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី ខេត្ត
- បង្កើតគណៈកម្មការសុខាភិបាល សម្រាប់ត្រួតពិនិត្យសុខភាព នៅទីឯកន្លែងជ្រើសរើស
- ធ្វើរបាយការណ៍អំពីលទ្ធផលកាតព្វកិច្ចយោធាជូនរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

មាត្រា៧.-

គ.ជ.ក. មានសិទ្ធិបង្កើតក្រុមការងារតាមតម្រូវការចាំបាច់។

ប្រធាន **គ.ជ.ក.** មានសិទ្ធិអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។

មាត្រា៨.-

គ.ទ.ក. មានសិទ្ធិប្រើប្រាស់ត្រាក្រសួងការពារជាតិ។

គ.ទ.ក. មាននាយកដ្ឋានបុគ្គលិកនៃក្រសួងការពារជាតិ ជាលេខាធិការដ្ឋាន។

ផ្នែកទី២

គណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី ខេត្ត

មាត្រា៩.-

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី ខេត្ត ហៅកាត់ថា **គ.ក.ក.ខ.** ដែលមានសមាសភាពដូចតទៅ ៖

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត	ប្រធាន
- មេបញ្ជាការរងយោធភូមិភាគ មួយរូប	អនុប្រធាន
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ឬមេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងខេត្ត	សមាជិកអចិន្ត្រៃយ៍
- ស្នងការនគរបាលរាជធានី ខេត្ត	សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថខេត្ត	សមាជិក
- ប្រធានមន្ទីរផែនការរាជធានី ខេត្ត	សមាជិក
- ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត	សមាជិក
- ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត	សមាជិក
- ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត	សមាជិក
- ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត	សមាជិក
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌចំណុះរាជធានី ខេត្ត	សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ក.ក.ខ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ទ.ក.**។

មាត្រា១០.-

គ.ក.ក.ខ. មានតួនាទីនិងភារកិច្ច ដូចតទៅ ៖

- ចាត់ចែង និងអនុវត្តគោលនយោបាយកាតព្វកិច្ចយោធា
- ដឹកនាំការធ្វើជំរឿនកាតព្វកិច្ចយោធា
- ដឹកនាំការជ្រើសរើស និងពិនិត្យកាយសម្បទា និងសុខភាពប្រជាពលរដ្ឋចូលបំពេញកាតព្វកិច្ចយោធា
- សម្រេចសមាសភាពប្រជាពលរដ្ឋ ដែលត្រូវអញ្ជើញចូលបំពេញកាតព្វកិច្ចយោធា
- សម្រេចអនុញ្ញាតចំពោះសមាសភាពប្រជាពលរដ្ឋ សុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា

និងសមាសភាពប្រជាពលរដ្ឋ មិនត្រូវចូលបំពេញភារកាតព្វកិច្ចយោធា

- ដឹកនាំការធានាសុវត្ថិភាពដល់ដំណើរការជ្រើសរើសប្រជាពលរដ្ឋ ចូលបំពេញភារកាតព្វកិច្ចយោធា ទូទាំងរាជធានី ខេត្តរបស់ខ្លួន
- ធ្វើរបាយការណ៍ជាប្រចាំអំពីលទ្ធផលនៃដំណើរការការងាររបស់ខ្លួនជូន **គ.ជ.ក.**
- បំពេញភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ក.** ប្រគល់ជូន។

មាត្រា១១.-

គ.ក.ស.ខ. មានកងរាជអាវុធហត្ថរាជធានី ឬតំបន់ប្រតិបត្តិការសឹករងខេត្ត ជាសេនាធិការ។

គ.ក.ស.ខ. មានសិទ្ធិប្រើប្រាស់ត្រារដ្ឋបាលរាជធានី ខេត្ត។

មាត្រា១២.-

គ.ក.ស.ខ. មានសិទ្ធិបង្កើតក្រុមការងារតាមតម្រូវការចាំបាច់។

ផ្នែកទី៣

គណៈកម្មាធិការកាតព្វកិច្ចយោធាមូលដ្ឋានឃុំ សង្កាត់

មាត្រា១៣.-

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាមូលដ្ឋានឃុំ សង្កាត់ ហៅកាត់ថា **គ.ក.ម.ស.** ដែលមានសមាសភាព ដូចតទៅ ៖

- អភិបាល ឬអភិបាលរងនៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ មួយរូប	ប្រធាន
- មេឃុំ ចៅសង្កាត់	អនុប្រធានអចិន្ត្រៃយ៍
- មន្ត្រីយោធាទទួលបន្ទុកកិច្ចការកាតព្វកិច្ចយោធា មួយរូប	អនុប្រធាន
- មន្ត្រីនគរបាលក្រុង ស្រុក ខណ្ឌ មួយរូប	អនុប្រធាន
- មន្ត្រីកងរាជអាវុធហត្ថ មួយរូប	សមាជិក
- មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មួយរូប	សមាជិក
- មន្ត្រីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មួយរូប	សមាជិក
- នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់	សមាជិក
- ស្មៀនឃុំ សង្កាត់	សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ក.ម.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ក.ស.ខ.**

មាត្រា១៤.-

គ.ក.ឃ.ស. មានតួនាទីនិងភារកិច្ច ដូចតទៅ ៖

- ទទួលខុសត្រូវក្នុងការធ្វើស្ថិតិ ការចុះបញ្ជីជំរឿនកាតព្វកិច្ចយោធា
- ចាត់ចែងការជ្រើសរើស ត្រួតពិនិត្យកាយសម្បទា និងសុខភាពដោយសហការជាមួយគណៈកម្មការសុខាភិបាល
- ធ្វើរបាយការណ៍ជាប្រចាំអំពីលទ្ធផលដំណើរការការងាររបស់ខ្លួនជូន **គ.ក.ន.ខ.**
- ជូនដំណឹងដល់សាមីជនដែលត្រូវបានជ្រើសរើសចូលបំពេញកាតព្វកិច្ចយោធា សាមីជនដែលត្រូវបានយល់ព្រមឱ្យពន្យារពេល
- បំពេញភារកិច្ចផ្សេងៗទៀតដែល **គ.ក.ន.ខ.** ប្រគល់ជូន។

មាត្រា១៥.-

គ.ក.ឃ.ស. មានសាលាឃុំ សង្កាត់ ជាសេនាធិការ។

គ.ក.ឃ.ស. មានសិទ្ធិប្រើប្រាស់ត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ជំពូកទី៣
ការធ្វើជំរឿន

មាត្រា១៦.-

ការធ្វើបញ្ជីជំរឿនកាតព្វកិច្ចយោធា ត្រូវប្រព្រឹត្តទៅពីដើមខែមករា រហូតដល់ដំណាច់ខែមីនា ជារៀងរាល់ឆ្នាំ ដោយ **គ.ក.ឃ.ស.**។

មាត្រា១៧.-

ការធ្វើបញ្ជីជំរឿនកាតព្វកិច្ចយោធា ត្រូវផ្អែកលើឯកសារណាមួយក្នុងចំណោមឯកសារដូចខាងក្រោម ៖

- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- សំបុត្រកំណើត
- ឯកសារផ្សេងៗដែលបញ្ជាក់សញ្ជាតិខ្មែរ។

សាមីខ្លួនត្រូវទៅចុះឈ្មោះដោយផ្ទាល់ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលជាអ្នកទៅចុះឈ្មោះជំនួស។

ប្រជាពលរដ្ឋដែលបានទៅចុះឈ្មោះក្នុងបញ្ជីជំរឿន ត្រូវទទួលបានបណ្ណជំរឿនកាតព្វកិច្ចយោធា។

មាត្រា១៨.-

ការធ្វើជំរឿនកាតព្វកិច្ចយោធា ត្រូវធ្វើចំពោះប្រជាពលរដ្ឋខ្មែរគ្រប់រូបលើកលែងតែ ៖

- ប្រជាពលរដ្ឋដែលបានបញ្ចប់សេវាជាយោធិនជាប់កិច្ចសន្យា
- ប្រជាពលរដ្ឋដែលកំពុងបម្រើការងារជាប្រយោជន៍សាធារណៈ ក្នុងកងយោធពលខេមរភូមិន្ទ ឬអ្នកមានឆ្នាំង

ក្នុងមាត្រា៣៥ នៃអនុក្រឹត្យនេះ

- ព្រះសង្ឃ បព្វជិតនៃសាសនាផ្សេងៗដែលមានការទទួលស្គាល់ពីក្រសួងធម្មការ និងសាសនា
- ប្រជាពលរដ្ឋពិការ
- ជនដែលកំពុងស្ថិតក្នុងពន្ធនាគារ ។

មាត្រា១៩.-

ពេលផ្លាស់ប្តូរទីលំនៅ ឬផ្លាស់ប្តូរអង្គភាព ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីជំរឿនកាតព្វកិច្ចយោធា ត្រូវរាយការណ៍ជូន **គ.ក.ឃ.ស.** ក្នុងឃុំ សង្កាត់ចាស់ដែលខ្លួនស្នាក់នៅ ហើយក្នុងរយៈពេលយ៉ាងយូរ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលទៅដល់ក្នុងឃុំ សង្កាត់ថ្មី សាមីខ្លួនត្រូវទៅសុំចុះឈ្មោះក្នុងបញ្ជីជំរឿនកាតព្វកិច្ចយោធារបស់ **គ.ក.ឃ.ស.** ក្នុងឃុំ សង្កាត់ថ្មីដែលខ្លួនរស់នៅ ។

មាត្រា២០.-

រៀងរាល់ឆ្នាំនៅដើមខែមករា ស្ថាប័នរដ្ឋ គ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស អង្គការ សមាគមនានា ត្រូវស្រង់ស្ថិតិ និងធ្វើបញ្ជីឈ្មោះមន្ត្រីបុគ្គលិកទាំងអស់ ដែលមានអាយុត្រូវចូលបំពេញកាតព្វកិច្ចយោធា ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនជូនដល់ **គ.ក.ឃ.ស.** នៅក្នុងមូលដ្ឋានឃុំ សង្កាត់ ដែលអង្គភាពរបស់ខ្លួនតាំងនៅ ព្រមទាំងក្រើនរំលឹកមន្ត្រីបុគ្គលិកក្រោមឱវាទឱ្យទៅចុះឈ្មោះក្នុង បញ្ជីជំរឿនកាតព្វកិច្ចយោធាឱ្យបានគ្រប់ៗគ្នា ។

អ្នកដែលបានចុះឈ្មោះក្នុងបញ្ជីជំរឿនរួចហើយ ត្រូវយកបណ្ណជំរឿនកាតព្វកិច្ចយោធាទៅបង្ហាញប្រធានអង្គភាព ឬស្ថាប័នរបស់ខ្លួន ។

ជំពូកទី៤

ការជ្រើសរើស

មាត្រា២១.-

នៅដើមខែសីហារៀងរាល់ឆ្នាំ **គ.ក.ឃ.ស.** ត្រូវចេញលិខិតអញ្ជើញប្រជាពលរដ្ឋ ដែលមានឈ្មោះក្នុងបញ្ជីជំរឿន ហើយរស់នៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីចូលរួមក្នុងការជ្រើសរើស និងពិនិត្យសុខភាពត្រៀមចូលបំពេញកាតព្វកិច្ចយោធា ។

មាត្រា២២.-

លក្ខណសម្បត្តិប្រជាពលរដ្ឋដែលត្រូវជ្រើសរើសឱ្យចូលបំពេញកាតព្វកិច្ចយោធា គឺមានកាយសម្បទា និងសុខភាពល្អ តាមការកំណត់ ។

ការពិនិត្យជ្រើសរើសត្រូវបែងចែកជាបីប្រភេទ ៖

- ប្រភេទទី១ គឺប្រជាពលរដ្ឋដែលមានកាយសម្បទា និងសុខភាពល្អគ្រប់គ្រាន់
- ប្រភេទទី២ គឺប្រជាពលរដ្ឋដែលមានកាយសម្បទា និងសុខភាពមធ្យម ដាក់ជាបម្រុងសម្រាប់ការជ្រើសរើសបំពេញបន្ថែម នៅពេលដែលប្រជាពលរដ្ឋប្រភេទទី១មិនគ្រប់តាមតម្រូវការ

- ប្រភេទទី៣ គឺប្រជាពលរដ្ឋដែលមានកាយសម្បទាមិនប្រក្រតី មិនត្រូវខ្វាត ឬមានជំងឺមិនអាចចូលបំពេញកាតព្វកិច្ចយោធាបាន។

ការរៀបរាប់លម្អិតអំពីលក្ខខណ្ឌកាយសម្បទា និងសុខភាពប្រជាពលរដ្ឋប្រភេទទី១ ទី២ និងទី៣ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

មាត្រា២៣.-

ប្រជាពលរដ្ឋត្រូវទទួលបានបណ្ណកាយសម្បទា និងសុខភាពកាតព្វកិច្ចយោធា តាមកម្រិតប្រភេទជាក់ស្តែងសម្រាប់សាមីខ្លួនម្នាក់ៗ ក្រោយពេលពិនិត្យកាយសម្បទា និងសុខភាពដោយ **គ.ក.ឃ.ស.** និងគណៈកម្មការសុខាភិបាលពិនិត្យនៅនឹងកន្លែងរួចហើយ។

មាត្រា២៤.-

ប្រធាន **គ.ក.ឃ.ស.** ត្រូវរាយការណ៍លទ្ធផលជ្រើសរើសជាបន្ទាន់ជូនដល់ **គ.ក.រ.ខ.**។

ក្នុងករណីមានបញ្ហាមិនប្រក្រតី ប្រធាន **គ.ក.ឃ.ស.** ត្រូវស្នើសុំមតិពី **គ.ក.រ.ខ.**។

មាត្រា២៥.-

គ.ក.ឃ.ស. ត្រូវរៀបចំការិយាល័យជ្រើសរើសនៅទីកន្លែងមួយជាសាធារណៈ។ ក្នុងករណីដែលប្រធានសក្តិកើតឡើងចំថ្ងៃជ្រើសរើស **គ.ក.ឃ.ស.** មានសិទ្ធិផ្អាកការជ្រើសរើសជាបណ្តោះអាសន្ន ហើយត្រូវរាយការណ៍ជាបន្ទាន់ជូនដល់ **គ.ក.រ.ខ.** និងរាយការណ៍តាមឋានានុក្រមជូនដល់រាជរដ្ឋាភិបាល។

ជំពូកទី៥

លក្ខខណ្ឌនៃការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា

មាត្រា២៦.-

សិស្ស និស្សិតដែលទទួលបានការអនុញ្ញាតតាមការស្នើសុំរបស់ខ្លួន ឱ្យពន្យារពេលចូលបំពេញកាតព្វកិច្ចយោធារួមមាន៖

- និស្សិតដែលកំពុងជាប់កម្មសិក្សា ឬស្រាវជ្រាវបញ្ចប់វគ្គជំនាញ ឬឯកទេស
- សិស្ស និស្សិតថ្នាក់ត្រៀមប្រឡង បរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ បរិញ្ញាបត្រវងមធ្យមសិក្សាបត្រទុតិយភូមិ ឬមធ្យមសិក្សាបត្របឋមភូមិ
- សិស្ស និស្សិតជាប់អាហារូបករណ៍ទៅរៀនក្រៅប្រទេស
- សិស្ស និស្សិតត្រូវទៅបន្តការសិក្សានៅក្រៅប្រទេស។

មាត្រា២៧.-

សិស្ស និស្សិតដែលសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធាត្រូវដាក់ជូន **គ.ក.ឃ.ស.** នូវពាក្យសុំពន្យារពេលរបស់ខ្លួនដោយបញ្ជាក់មូលហេតុ និងមានការបញ្ជាក់ពីប្រធានគ្រឹះស្ថានសិក្សា។

ការសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវបានទទួលស្គាល់ថាមានការអនុញ្ញាតជាផ្លូវការ លុះត្រាតែមានលិខិតជូនដំណឹងពី **គ.ក.ឃ.ស.** យោងតាមសេចក្តីសម្រេចឯកភាពពី **គ.ក.ន.ខ.** ។ **គ.ក.ឃ.ស.** ត្រូវដកហូតបណ្ណកាយសម្បទា និងសុខភាពកាតព្វកិច្ចយោធា ទុកដើម្បីធ្វើការពិនិត្យឡើងវិញនៅពេលអញ្ជើញលើកក្រោយ។

ការឆ្លើយតបចំពោះសិស្ស និស្សិតដែលបានដាក់ពាក្យសុំពន្យារពេល ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ យ៉ាងយូរក្រោយពេលទទួលពាក្យសុំរបស់សាមីខ្លួន។

រាល់ការពន្យារពេលត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំដោយ **គ.ក.ឃ.ស.** ។

ជំពូកទី៦

លក្ខខណ្ឌនៃការពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា

សម្រាប់ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស

មាត្រា២៨.-

ប្រជាពលរដ្ឋដែលត្រូវបានអនុញ្ញាតឱ្យពន្យារពេលចូលបំពេញកាតព្វកិច្ចយោធារួមមាន ៖

- ប្រជាពលរដ្ឋដែលជាកម្លាំងពលកម្មតែម្នាក់ឯងគត់ក្នុងគ្រួសារ ហើយទទួលបន្ទុកចិញ្ចឹមមនុស្ស ដែលមិនទាន់ដល់អាយុពេញពលកម្ម ឬចាស់ជរា ឬពិការច្រើននាក់
- ប្រជាពលរដ្ឋជាកូនកំព្រាតែម្នាក់គត់ដែលឪពុក ឬម្តាយបានពលីក្នុងសមរភូមិ
- ប្រជាពលរដ្ឋជាកូនទោលក្នុងគ្រួសារដែលមានតែម្តាយនិងកូន ឬឪពុកនិងកូន
- ប្រជាពលរដ្ឋពោះម៉ាយ ដែលមានកូនច្រើននាក់នៅក្នុងបន្ទុក
- ប្រជាពលរដ្ឋដែលកំពុងសម្រាកព្យាបាលជំងឺ
- ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងស្ថានភាពរងគ្រោះ ក្នុងករណីប្រធានសត្តិ និងគ្រោះធម្មជាតិ
- ប្រជាពលរដ្ឋដែលត្រូវទៅរស់នៅជាមួយឪពុកម្តាយ ដែលបំពេញបេសកកម្មរយៈពេលវែង នៅក្រៅប្រទេស
- មន្ត្រីរាជការដែលត្រូវទៅបំពេញការងារនៅបរទេសមានរយៈពេលចាប់ពី៣ (បី) ខែឡើង
- សាស្ត្រាចារ្យ គ្រូបង្រៀនក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា
- កម្មករដែលជាអ្នកជំនាញឯកទេសក្នុងរោងចក្រ សហគ្រាស ហើយដែលមិនអាចរកអ្នកជំនួសបានភ្លាមៗ
- និយោជកដែលទទួលបន្ទុកដឹកនាំការងារជំនាញ ឬឯកទេសក្នុងសហគ្រាស ហើយដែលមិនអាចរកអ្នកជំនួសបានភ្លាមៗ។

មាត្រា២៩.-

ប្រជាពលរដ្ឋដែលសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវដាក់ជូន **គ.ក.ឃ.ស.** នូវពាក្យសុំពន្យារពេលរបស់ខ្លួន ដោយបញ្ជាក់មូលហេតុ និងមានការបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់។

មន្ត្រីរាជការដែលជាប់បេសកកម្មទៅបំពេញភារកិច្ចនៅក្រៅប្រទេស ត្រូវដាក់ជូន **គ.ក.ឃ.ស.** នូវពាក្យសុំ

ពន្យារពេលរបស់ខ្លួនដោយបញ្ជាក់មូលហេតុ និងមានការបញ្ជាក់ពីក្រសួង ស្ថាប័នសាមី។

និយោជក កម្មករ និយោជិតដែលសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវដាក់ជូន **គ.ក.ឃ.ស.** នូវពាក្យសុំពន្យារពេលរបស់ខ្លួន ដោយមានការបញ្ជាក់ពីប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត។

មាត្រា៣០.-

ការសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវបានទទួលស្គាល់ថា បានការអនុញ្ញាតជាផ្លូវការ លុះត្រាតែបានទទួលលិខិតជូនដំណឹងពី **គ.ក.ឃ.ស.** យោងតាមសេចក្តីសម្រេចឯកភាពរបស់ **គ.ក.ន.ខ.**។

ការឆ្លើយតបចំពោះប្រជាពលរដ្ឋស្ថិតក្នុងករណីពិសេស ដែលបានដាក់ពាក្យសុំពន្យារពេល ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ យ៉ាងយូរក្រោយពេលបានទទួលពាក្យសុំ របស់សាមីខ្លួន។

រាល់ការពន្យារពេលត្រូវពិនិត្យឡើងវិញរៀងរាល់ឆ្នាំដោយ **គ.ក.ឃ.ស.**។

គ.ក.ឃ.ស. ត្រូវដកហូតបណ្ណកាយសម្បទា និងសុខភាពកាតព្វកិច្ចយោធា ទុកដើម្បីធ្វើការអញ្ជើញនៅលើកក្រោយ។

ជំពូកទី៧

ការអញ្ជើញចូលបំពេញកាតព្វកិច្ចយោធា

មាត្រា៣១.-

ការសម្រេចទទួលឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវ ៖

- ទទួលយកមុនគេប្រជាពលរដ្ឋដែលស្នើសុំចូលបំពេញកាតព្វកិច្ចយោធា
- ធ្វើការចាប់ឆ្នោតនៅពេលប្រជាពលរដ្ឋដែលស្នើសុំចូលបំពេញកាតព្វកិច្ចយោធា មានចំនួនច្រើន ឬតិចជាងតម្រូវការ។

មាត្រា៣២.-

គ.ក.ន.ខ. ត្រូវចេញសេចក្តីសម្រេចអញ្ជើញប្រជាពលរដ្ឋឱ្យចូលបំពេញកាតព្វកិច្ចយោធា តាមចំនួនតម្រូវការប្រចាំឆ្នាំ។

គ.ក.ឃ.ស. ត្រូវជូនសេចក្តីសម្រេចអញ្ជើញប្រជាពលរដ្ឋឱ្យចូលបំពេញកាតព្វកិច្ចយោធាដល់សាមីខ្លួន ដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរឃុំ សង្កាត់ ឬប្រធានអង្គភាព ក្រសួង មន្ទីរ រោងចក្រ សហគ្រាស ឬគ្រឹះស្ថានសិក្សា ក្នុងរយៈពេលយ៉ាងតិច៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃកំណត់ចូលបង្ហាញខ្លួន។

មាត្រា៣៣.-

ប្រជាពលរដ្ឋដែលមានឈ្មោះអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវមកបង្ហាញខ្លួនតាមកាលវិភាគ ទីកន្លែង ដែលកំណត់ក្នុងសេចក្តីសម្រេចអញ្ជើញ។

ប្រជាពលរដ្ឋដែលត្រូវមកបង្ហាញខ្លួន ត្រូវយកមកជាមួយនូវឯកសារមួយចំនួនដូចជា ៖

- សេចក្តីសម្រេចអញ្ជើញប្រជាពលរដ្ឋឱ្យចូលបំពេញកាតព្វកិច្ចយោធា
- វិញ្ញាបនបត្រសិក្សា វិញ្ញាបនបត្រឯកទេស ឬសញ្ញាបត្រផ្សេងៗទៀត ប្រសិនបើមាន
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណបណ្ណសិស្ស និស្សិត ។

ជំពូកទី៨
បទប្បញ្ញត្តិដោយឡែក

មាត្រា៣៤.-

ក្រសួងការពារជាតិ ត្រូវចេញបណ្ណបំពេញកាតព្វកិច្ចយោធាឱ្យប្រជាពលរដ្ឋ ដែលបានបញ្ចប់កាតព្វកិច្ចយោធា និងប្រជាពលរដ្ឋដែលបានបំពេញបេសកកម្ម ជាប្រយោជន៍សាធារណៈ ក្នុងកងយោធពលខេមរភូមិន្ទ ក្នុងរយៈពេលគ្រប់១៨ (ដប់ប្រាំបី) ខែ ។

មាត្រា៣៥.-

អ្នកឯកទេសជំនាញវិជ្ជាជីវៈដែលមានបំណងចុះកិច្ចសហប្រតិបត្តិការបំពេញបេសកកម្ម ស្មារជ្រាវ ឬអនុវត្តផ្ទាល់នូវកិច្ចការដែលជាប្រយោជន៍សាធារណៈនៃកងយោធពលខេមរភូមិន្ទ ដែលមានរយៈពេលស្មើនឹងស្ថានភាពកាតព្វកិច្ចយោធាចំនួន១៨ (ដប់ប្រាំបី) ខែ ដើម្បីរួចផុតពីកាតព្វកិច្ចយោធា ត្រូវដាក់ពាក្យនៅក្រសួងការពារជាតិ ។

កិច្ចការនៃអ្នកឯកទេសជំនាញវិជ្ជាជីវៈទាំងនោះរួមមានសេវា ៖

- ផ្នែកវិស្វកម្ម ស្ពានថ្ពល់ និងសំណង់
- ផ្នែកបោសសំអាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ
- ផ្នែកសុខាភិបាល
- ផ្នែកទូរគមនាគមន៍
- ផ្នែកព័ត៌មានវិទ្យា ។

មាត្រា៣៦.-

ការគ្រប់គ្រង ការចាត់តាំង ការហ្វឹកហ្វឺន ការធានាជីវភាពយោធិនបំពេញកាតព្វកិច្ចយោធា និងការអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់ភាពស៊ីវិលវិញ នៃប្រជាពលរដ្ឋដែលបានបំពេញកាតព្វកិច្ចយោធាចប់ ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ និងអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ។

ការហ្វឹកហ្វឺនបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាទិភាពក្នុងការរកការងារឱ្យធ្វើសម្រាប់ប្រជាពលរដ្ឋដែលបានបំពេញកាតព្វកិច្ចយោធា និង/ឬការបញ្ជូនទៅក្នុងក្របខណ្ឌដើមរបស់ក្រសួង មន្ទីរ សហគ្រាស ឬក្រុមហ៊ុនឯកជន

របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង/ឬ ស្ថាប័នដើម ឬអង្គភាពដើមរបស់សាមីខ្លួន និង/ឬ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

មាត្រា៣៧.-

ធនធានសម្រាប់ធានារ៉ាល់ការចំណាយ ក្នុងការអនុវត្តកាតព្វកិច្ចយោធា គឺត្រូវបញ្ចូលក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងការពារជាតិ។

ជំពូកទី៩
អវសានប្បញ្ញត្តិ

មាត្រា៣៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៩
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៩៣០.អនក.ឋ

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាតំណ្ឌ
៣៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងធម្មការនិងសាសនា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាតំណ្ឌ** ថ្នាក់ **ធិបឌិន្ត** ជូនលោក **ម៉ាណាវ អាពូម៉ាកើ** សប្បុរសជននៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយទិញដីកសាងវិហារឥស្លាម ធ្វើរបង ចាក់ដីបំពេញទីធ្លា និងកសាងអគារសិក្សា នៅភូមិក្រោលក្របី ស្រុកបាកាន ខេត្តពោធ៍សាត់ ចំណាយអស់ទឹកប្រាក់សរុបចំនួន ៩០.១១៥ ដុល្លារ អាមេរិក ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលខេត្តពោធ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៧៣១ រ.ន.ត/ត.ន

អនុក្រឹត្យ

ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល
មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ ៨ស.រកម.០៦៩៦.០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១២០៤.០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

សម្រេច

មាត្រា ១.-

តែងតាំងសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ "ម.អ.ជ." សម្រាប់អាណត្តិទី ៣ ដែលមានសមាសភាព ដូចខាងក្រោម:

១.	ឯកឧត្តម **ស៊ុយ សែម**	រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	ជាប្រធាន
២.	ឯកឧត្តម **ស៊ីម សុន**	រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	ជាអនុប្រធាន
៣.	ឯកឧត្តម **សួង ម៉ែងគា**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាអនុប្រធាន
៤.	ឯកឧត្តម **ឡី នរិន្ទ**	ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា	ជាសមាជិក
៥.	លោក **ជាប សត្ថារតន៍**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
៦.	លោក **សរ គីនីរ៉ា**	តំណាងក្រសួងមហាផ្ទៃ	ជាសមាជិក
៧.	លោក **ថេង បញ្ញាធន**	តំណាងក្រសួងផែនការ	ជាសមាជិក
៨.	លោកស្រី **Julia Brickell**	តំណាងដៃគូអភិវឌ្ឍន៍	ជាសមាជិក
៩.	លោក **អ៊ែនឌី ភាំង**	តំណាងសហគមធនាគារិកកម្ពុជា	ជាសមាជិក
១០.	លោក **គង់ ពុទ្ធី**	តំណាងអ្នកមានអាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនីដែលបានចូលរួមក្នុងគំរោងអភិវឌ្ឍន៍អគ្គិសនីជនបទ	ជាសមាជិក
១១.	លោក **សាង ហាក់**	តំណាងអង្គការក្រៅរដ្ឋាភិបាលដែលបានចូលរួមក្នុងគំរោងអភិវឌ្ឍន៍អគ្គិសនីជនបទ	ជាសមាជិក
១២.	លោក **ស៊ីម តារា**	តំណាងអ្នកប្រើប្រាស់អគ្គិសនីជនបទ	ជាសមាជិក ។

មាត្រា ២.-

ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលមានជាអាទិ:

១. អនុម័តគោលនយោបាយ និងនីតិវិធីប្រចាំឆ្នាំក្នុងការប្រើប្រាស់មូលនិធិ "ម.អ.ជ."

២. ជ្រើសរើសនាយកប្រតិបត្តិនៃលេខាធិការដ្ឋាន "ម.អ.ជ."

៣. អនុម័តរចនាសម្ព័ន្ធអង្គការចាត់តាំង គោលនយោបាយបុគ្គលិក បទបញ្ជាផ្ទៃក្នុងរបស់ "ម.អ.ជ."

៤. តាមដានពិនិត្យលើការគ្រប់គ្រង កិច្ចប្រតិបត្តិការរបស់លេខាធិការដ្ឋាន "ម.អ.ជ."

៥. ជ្រើសរើសភ្នាក់ងារទូទាត់របស់ "ម.អ.ជ."

៦. រៀបចំលក្ខន្តិក:សំរាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃ "ម.អ.ស".។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អាជ្ញាធរអគ្គិសនីកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-ឯកសារ-កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៧៣២.អនត.៨៨

អនុក្រឹត្យ

ស្តីពី

ការជូនគ្រឿងឥស្សរិយយស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

ស ម្រេ ច

មាត្រា ១ : បំពាក់ **គ្រឿងឥស្សរិយយស** តាមប្រភេទ និងលំដាប់ថ្នាក់ ជូន ឥស្សរជន សប្បុរសជន មន្ត្រីរាជការ ចំនួន **៤០៤ នាក់** ដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ច និងគុណបំណាច់ក្នុងការជួយកសាងសមិទ្ធផលគ្រប់វិស័យ រួមចំណែកស្តារ និងអភិវឌ្ឍន៍ ស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

ក. មេជាយមុនីសារាតំណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម	**ខីម**	**ជាសោតំណ្ឌ**	អគ្គនាយកអធិការកិច្ចក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
២-ឯកឧត្តម	**ជ្ជក**	**ចាន់ណារិទ្ធ**	ប្រធាននាយកដ្ឋានក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៣-លោក	**អៀង**	**ណារិន**	ជំនួយការផ្ទាល់ឯកឧត្តម **ចល់ រឿម**
៤-ឯកឧត្តម	**ចៅ**	**សម្បត្តិ**	នាយករងមន្ទីរពេទ្យព្រះកេតុមាលា

៥-ឯកឧត្តម	ថោ	ថេជ្ជា	ជំនួយការផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
៦-លោក	សរ	គីមសាន	អនុប្រធាននាយកដ្ឋាន ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
៧-លោក	ចយ	សុមិន	អភិបាលស្រុកកណ្តាលស្ទឹង
៨-លោក	រាជ	ឧណ្ណារិទ្ធ	នាយផ្នែក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ
៩-លោក	ហែន	មិន្តា	អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកល្វាឯម
១០-លោក	សេង	រីណូ	មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកលើកដែក

ខ- មេដាយមុនីសារាភំណ្ឌ ថ្នាក់ សេនា :

១-លោក	លី	ជាល្ងី	អនុប្រធាននាយកដ្ឋានក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
២-លោក	ហួត	ហាក់	ប្រធាននាយកដ្ឋានរដ្ឋបាលបុគ្គលិកក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
៣-លោក	មាន	តារ៉ុង	ប្រធានផ្នែកថែទាំ និងដឹកជញ្ជូនមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៤-ឯកឧត្តម	មុន្នី	ហោរ៉ាត	នាយកទីចាត់ការបំភណ្ឌ័អក្ខរៈ ក្រសួងការពារជាតិ
៥-ឯកឧត្តម	សៅ	សៀម	នាយករងខុទ្ទការល័យអគ្គបញ្ជាការកងយោធពលខេមរៈភូមិន្ទ
៦-លោក	ម៉ុន	សំបុត្រ	ប្រធានការិយាល័យពិធីការ អាកាសចរណ៍ស៊ីវិលកម្ពុជា
៧-លោក	មាន់	រស្មី	អនុប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក
៨-លោក	មាស	ឧណ្ណា	នាយការិយាល័យបច្ចេកទេសអគ្គបញ្ជាការកងយោធពលខេមរៈភូមិន្ទ
៩-លោក	មិន	សេន	ជំនួយការឯកឧត្តម **មល់ រ៉ៀម**
១០-ឯកឧត្តម	ថាច់	ឧណ្ណៈ	អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
១១-លោក	អ៊ូ	ស៊ីយុន	អភិបាលរងស្រុកល្វាឯម
១២-លោក	សុខ	ធី	អនុប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១៣-លោក	ធិន	សុខសាម៉ុឌី	ប្រធាននាយកដ្ឋានក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច

គ- មេដាយមុនីសារាភំណ្ឌ ថ្នាក់ អសម្បូទ្ធិ :

១-លោក	សុខ	ផល្លា	អនុប្រធាននាយកដ្ឋានក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
២-លោក	ធា	គ្រួយ	អនុប្រធានសមាគមន៍គ្រូពេទ្យកម្ពុជា
៣-លោក	សំ	សែនចំរ៉ុង	អនុប្រធាននាយកដ្ឋានក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៤-លោក	នាក់	សុខា	ប្រធានការិយាល័យក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៥-លោក	អ៊ុំ	តូមិរ៉ូ	ប្រធាននាយកដ្ឋានផែនការប្រតិបត្តិការមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៦-លោក	ស្រី	មាន់ផល្លី	អនុប្រធាននាយកដ្ឋានអធិការកិច្ចក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៧-លោក	ហ៊ុម	ឧ៉ាន់ឌី	អនុប្រធាននាយកដ្ឋានប្រតិបត្តិការ និង ផែនការមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា

៨-លោក	ពិន	អ៊ុច	អនុប្រធាននាយកដ្ឋានក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
៩-លោក	ឡេង	ជ្រោង	ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និង ធនធានមនុស្សមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុ
១០-លោក	គីម	តូ	អនុប្រធាននាយកដ្ឋានក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
១១-លោក	សេង	សារី	មន្ត្រីគយ-រដ្ឋករក្រុងព្រះសីហនុ
១២-លោក	សំ	សាម្បឿន	ប្រធានការិយាល័យប្បៀវត្សអាកាសចរណ៍ស៊ីវិលកម្ពុជា
១៣-លោក	ណុប	ចិន្តារិទ្ធ	អនុប្រធានការិយាល័យបុគ្គលិក រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា
១៤-លោក	សុខ	ឡេង	ប្រធានការិយាល័យរដ្ឋបាលនាយកដ្ឋានគ្រឿងយន្តកសិកម្ម
១៥-លោក	រស់	សុខឆ្បើន	ប្រធាននាយកដ្ឋានអង្គភាពអន្តរាគមន៍ នគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ
១៦-លោក	តូ	សាធី	នាយកវិទ្យាល័យទឹកឃ្លាំងស្រុកល្វាឯម
១៧-លោក	ឃី	សោតិណារិទ្ធ	ប្រធានការិយាល័យសុខភិបាលស្រុកល្វាឯម និងជាអនុប្រធានប្រតិបត្តិស្រុកក្បាងស្វាយ
១៨-លោក	ហ៊ឹម	សារ៉ាន់	នាយករងផ្នែកស្រាវជ្រាវ ក ២
១៩-លោក	គីម	សុខជា	អនុប្រធាននាយកដ្ឋានរដ្ឋបាលបុគ្គលិកក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
២០-លោក	ប៊ុន	តារី	នាយករងមន្ទីពេទ្យព្រះកេតុមាលា
២១-លោក	ចឹង	ឃ្បើន	អធិការនគរបាលស្រុកល្វាឯម
២២-លោកស្រី	សរ	សាលីម	អភិបាលរងស្រុកល្វាឯម
២៣-លោក	ឆួច	ខេង	នាយកវិទ្យាល័យអរិយក្សត្រ
២៤-លោក	ឆ្លុង	ឬទ្ធី	អនុប្រធានការិយាល័យអប់រំ យុវជន និង កីឡាស្រុកល្វាឯម
២៥-លោក	ញ៉ឹក	សាត	ប្រធានការិយាល័យរដ្ឋបាលសាលាស្រុកល្វាឯម
២៦-លោក	ញ៉ៅម	សារ៉ន	ប្រធានការិយាល័យកសិកម្មស្រុកល្វាឯម
២៧-លោក	ឈរ	តុងឈាង	ប្រធានមន្ទីសាលាស្រុកល្វាឯម
២៨-លោក	មាស	អ៊ី	ប្រធានការិយាល័យអប់រំ យុវជន និង កីឡាស្រុកល្វាឯម
២៩-លោក	ឡាំ	ឡើន	អនុប្រធានការិយាល័យអប់រំ យុវជន និង កីឡាស្រុកល្វាឯម
៣០-លោក	ឆេត	សំអុល	ប្រធានការិយាល័យសង្គមកិច្ច និង អតីតយុទ្ធជនស្រុកល្វាឯម
៣១-លោក	ជា	ថុល	អធិការរងនគរបាលស្រុកល្វាឯម
៣២-លោក	មាស	ណារិន	ប្រធានការិយាល័យធនធានទឹក និង ឧតុនិយមស្រុកល្វាឯម
៣៣- លោក	អ៊ុត	ចាន់ថេ	ប្រធានការិយាល័យផែនការស្រុកល្វាឯម
៣៤-លោក	ឈិត	សាឡើន	មន្ត្រីផ្នែករដ្ឋបាលការិយាល័យសុខាភិបាលស្រុកល្វាឯម
៣៥-លោក	ឃិន	រិន	មន្ត្រីជំនួយការឯកឧត្តម **ឃុត ឆេ**

៣៦-លោកវេជ្ជបណ្ឌិត	ជា	ឆៅ	មន្ត្រីមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ
៣៧-ឯកឧត្តម	ហ៊ុន	ហេង	ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
៣៨-លោក	ម៉ុន	ខៀង	វេជ្ជបណ្ឌិត មន្ទីរពេទ្យជ័យជំនះ
៣៩-លោក	លន់	ឌុំ	ប្រធានការិយាល័យបិរស្ថានស្រុកល្វាឯម
៤០-លោក	សុធា	អរុណ	ជំនួយការឯកឧត្តម កែវ សាផល
៤១-លោក	ញ៉ៅប	សែ	ប្រធានសវនកម្មមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៤២-លោក	ចន្ទំ	សម្បត្តិ	ប្រធានការិយាល័យគំរោងផ្សព្វផ្សាយមីន
៤៣-លោក	សម	ទាសនា	មន្ត្រីត្រួតពិនិត្យគុណភាពសំភារៈមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៤៤-លោក	ញ៉ៅប	សូរ	ប្រធានរោងជាងកណ្តាលមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៤៥-លោក	កេត	សេងយ៉ុម	ប្រធានមន្ទីរទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ចខេត្តកណ្តាល
៤៦-លោក	ម្ចូន	សុណា	អនុប្រធាននាយកដ្ឋានក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
៤៧-លោកអនុសេនីយ៍ទោ	ជៃ	សេងហ៉ាង	អធិការរងនគរបាលស្រុកព្រះស្តេច ខេត្តព្រៃវែង
៤៨-លោកអនុសេនីយ៍ទោ	សេង	សាវ៉ន	អធិការរងនគរបាលស្រុកព្រះស្តេច ខេត្តព្រៃវែង

ឃ-មេជាយមាសការទារ :

១-ឯកឧត្តម	កែវ	សុផ្ឆា	អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ
២-លោក	សេង	ស្ត្រុន	ប្រធានការិយាល័យក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៣-លោក	យ៉ាន់	ពន្លក	ប្រធានការិយាល័យក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៤-លោក	ខៀវ	សិន	អនុប្រធានការិយាល័យក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
៥-លោក	សោម	សារ៉ែត	អនុប្រធានការិយាល័យរដ្ឋបាលមន្ទីរសាធារណៈការខេត្តកណ្តាល
៦-លោក	គុន	សុវណ្ណ	មន្ត្រីដឹកជញ្ជូន មន្ទីរសាធារណៈការដឹកជញ្ជូនខេត្តកណ្តាល
៧-លោក	ឡាក់	សុខុន	ប្រធានការិយាល័យផែនការ សេដ្ឋកិច្ចសង្គមមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៨-លោក	រត្ថ៍	ពុធតាណា	ប្រធានកងឯកភាព បោសសំអាតមីនមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៩-លោក	ស៊ុន	ម៉ុន	ប្រធានការិយាល័យធនធានមនុស្សមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
១០-លោក	ពេញ	សាវ៉ាត	នាយផ្នែកហ្វឹកហ្វឺនសុខាភិបាលមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
១១-លោក	ឆេព	សាគ្យ៉ែន	នាយផ្នែកកំទេចគ្រឿងផ្ទុះមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
១២-លោក	រី	ព្រ៉ី	អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អាកាសចរណ៍ស៊ីវិលកម្ពុជា
១៣-លោក	ម្យ៉ែន	សាខន	អនុប្រធានការិយាល័យបុគ្គលិកអាកាសចរណ៍ស៊ីវិលកម្ពុជា
១៤-លោក	ឃុន	ហ៊ុ	អនុប្រធាននាយកដ្ឋានផែនការអាកាសចរណ៍ស៊ីវិលកម្ពុជា
១៥-លោក	ថុង	និច	អនុប្រធានការិយាល័យហិរញ្ញកិច្ចអាកាសចរណ៍ស៊ីវិលកម្ពុជា
១៦-លោក	គីម	ទុទ្ធី	ប្រធានការិយាល័យរដ្ឋបាលទូទៅ អាកាសចរណ៍ស៊ីវិលកម្ពុជា
១៧-លោក	ជៀវ	ទ៉ីន	អនុប្រធានការិយាល័យអគ្គីសនី អាកាសចរណ៍ស៊ីវិលកម្ពុជា

១៨-លោក	សួន	តូមា	អនុប្រធានការិយាល័យប្បៀវត្ស អាកាសចរណ៍ស៊ីវិលកម្ពុជា
១៩-លោក	សុខ	សុខា	អនុប្រធានការិយាល័យ
២០-លោក	ញ៉ឹក	សារឹម	អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុអាកាសចរណ៍ស៊ីវិលកម្ពុជា
២១-លោកវេជ្ជបណ្ឌិត	ខ្វាន់	ប៊ុណ្ណា	មន្ត្រីក្រសួងសុខាភិបាល
២២-លោក	សោម	សក្ខុណា	ប្រធានការិយាល័យគ្រឿងយន្តអាកាសចរណ៍ស៊ីវិលកម្ពុជា
២៣-លោក	អ៊ឿន	ខេមុន្នី	អនុប្រធានការិយាល័យហិរញ្ញកិច្ចអាកាសចរណ៍ស៊ីវិលកម្ពុជា
២៤-លោក	ឡាច	សុថីណា	មន្ត្រីក្រសួងទេសចរណ៍
២៥-លោក	ស៊ឹម	សុច្ឆិដ្ឋា	មន្ត្រីហិរញ្ញវត្ថុមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៦-លោក	សម	ខាន់ថុល	មន្ត្រីហិរញ្ញវត្ថុមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧-លោក	ពូក	ប៊ុនច្បើន	មន្ត្រីភស្តុភា មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៨-លោក	ហ៊ាច	រិទ្ធ	មន្ត្រីក្រសួងទេសចរណ៍
២៩-លោក	ខ៊ា	សុវណ្ណពិសាល	អនុប្រធានការិយាល័យអធិការកិច្ចនិងសន្តិសុខទី១ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
៣០-លោក	ហុច	គារ៉ី	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៣១-លោក	ជិល	សារឿន	នាយករងផ្នែកសំភារៈមន្ទីរពេទ្យព្រះកេតុមាលា
៣២-លោក	ហៃ	ឈីមគ្រី	នាយកការិយាល័យបុគ្គលិកមន្ទីរពេទ្យព្រះកេតុមាលា
៣៣-លោក	ពាន់	ឌិន	នាយកការិយាល័យហិរញ្ញវត្ថុ មន្ទីរពេទ្យព្រះកេតុមាលា
៣៤-លោក	កើត	ស៊ីយុត្តិ	នាយកការិយាល័យភស្តុភារ មន្ទីរពេទ្យព្រះកេតុមាលា
៣៥-លោក	សុខ	ឃូដេត	នាយករងការិយាល័យហិរញ្ញវត្ថុ មន្ទីរពេទ្យព្រះកេតុមាលា
៣៦-លោក	ប៊ី	ប៊ុនថុន	នាយកអាគារពិនិត្យ មន្ទីរពេទ្យព្រះកេតុមាលា
៣៧-លោកវេជ្ជបណ្ឌិត	ស្រួយ	អាដុង្ហា	មន្ត្រីក្រសួងសុខាភិបាល
៣៨-លោក	ម៉ិច	ចាន់តារា	នាយកអាគារវះកាត់ច្រួង មន្ទីរពេទ្យព្រះកេតុមាលា
៣៩-លោក	សុខ	ហោច	នាយករងការិយាល័យភស្តុភារ មន្ទីរពេទ្យព្រះកេតុមាលា
៤០-លោក	គីម	សុខាឬទ្ធិ	នាយករងសង្គ្រោះក្រោយវះកាត់ មន្ទីរពេទ្យព្រះកេតុមាលា
៤១-លោក	សួរ	ឌុំ	នាយករងជំងឺក្រពះ ពោះវៀន មន្ទីរពេទ្យព្រះកេតុមាលា
៤២-លោក	សេក	សុតំណូ	ទន្តពេទ្យ មន្ទីរពេទ្យព្រះកេតុមាលា
៤៣-លោក	ឃិន	ចាន់ឌី	ទន្តបណ្ឌិត មន្ទីរពេទ្យព្រះកេតុមាលា
៤៤-លោក	ហុច	សីរីវុឌ្ឍ	នាយអាគារជំងឺទូទៅ មន្ទីរពេទ្យព្រះកេតុមាលា
៤៥-លោក	កែវ	ជាវុធ	នាយកអាគារជំងឺតំរងនោម មន្ទីរពេទ្យព្រះកេតុមាលា

៤៦-លោក	ឆង	សារ៉ាវី	នាយរងសង្គ្រោះក្រោយវះកាត់ មន្ទីរពេទ្យព្រះកេតុមាលា
៤៧-លោក	កែវ	ណារិទ្ធ	នាយករងអាគារតំរងនោម មន្ទីរពេទ្យព្រះកេតុមាលា
៤៨-លោក	ចឺ	សារ៉ែន	ទន្តពេទ្យ មន្ទីរពេទ្យព្រះកេតុមាលា
៤៩-លោក	ឆុក	សារ៉ុត	ទន្តបណ្ឌិត មន្ទីរពេទ្យព្រះកេតុមាលា
៥០-លោក	ថោង	ខ្វឺត	មេបញ្ជាការកងរាជអាវុធហត្ថស្រុកល្វាឯម
៥១-លោក	ម៉ុក	សេរីសម្បត្តិ	នាយផ្នែកជំងឺជនក្រីក្រ មន្ទីរពេទ្យព្រះកេតុមាលា
៥២-លោក	ឆង	ចាន់តារា	លេខាផ្ទាល់ ឯកឧត្តម **ចៅ តិរុណ**
៥៣-លោក	ជា	ពេញ	ជំនួយការ ឯកឧត្តម **ឃុច សុវណ្ណារី**
៥៤-លោក	សេង	ហួរ	ប្រធានការិយាល័យគណនេយ្យមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៥៥-លោក	ឡុង	សាឆុង	នាយផ្នែកផ្គត់ផ្គង់ មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៥៦-លោក	សរ	ឆាយ៉ា	នាយផ្នែកសើបអង្កេតមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៥៧-លោក	រ័ត្ន	សុធារិទ្ធ	នាយផ្នែកហិរញ្ញវត្ថុមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៥៨-លោក	ហោង	ក្រា	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៥៩-លោក	តាំង	សាម៉ឿន	ក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**នាយករដ្ឋមន្ត្រី
៦០-លោក	ឡុង	ពិជ	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៦១-លោក	ជៀម	ទីតា	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៦២-លោក	ក្រាដ្ឋ	សុតំគ្រា	ក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**នាយករដ្ឋមន្ត្រី
៦៣-លោក	ហ៊ុន	សុខីណាំង	បុគ្គលិកផ្នែកនីតិកម្មធានាគារអេស៊ីលីដា
៦៤-លោក	ព្រឿង	បញ្ញារិទ្ធ	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៦៥-លោក	គួក	ឆុន្នី	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៦៦-លោក	សែម	សុគន្ធា	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៦៧-លោក	ឃុន	រតនា	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៦៨-លោក	យ៉ុង	យី	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៦៩-លោក	ឃួន	ទាសនា	អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៧០-លោក	ម៉ុង	សុគន្ធារដ្ឋ	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៧១-លោក	កៅ	សាវ៉ាត	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៧២-លោក	អ៊ូច	អូន	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៧៣-លោក	ប៊ុន	រ៉ែត	អនុប្រធានមន្ទីរទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ចខេត្តកណ្តាល

៧៤-លោក	ឃួន	ចូរ៉ាត	ប្រធានការិយាល័យដឹកជញ្ជូននៃមន្ទីរសាធារណៈការខេត្តកណ្តាល
៧៥-លោក	ឃុត	ឡួចឌី	អនុប្រធាននាយកដ្ឋានក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៧៦-លោក	ឆាង	ប៊ុនឆឿន	ប្រធានការិយាល័យក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៧៧-លោក	ឆា	ជូលីន	ប្រធានការិយាល័យក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៧៨-លោក	ឆុត	ពៅវិចិត្រ	ប្រធានការិយាល័យក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៧៩-លោក	ចេង	ឆេង	អនុប្រធាននាយកដ្ឋានក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៨០-លោក	ជូ	ចូរិន	អនុប្រធានការិយាល័យក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
៨១-លោក	ស្រីច	ថាវុធ	អនុប្រធានការិយាល័យនៃមន្ទីរសាធារណៈការខេត្តកណ្តាល
៨២-លោក	ជា	សារ៉ាន់	អនុប្រធានអង្គភាពស្តាន ថ្នល់ នៃមន្ទីរសាធារណៈការខេត្តកណ្តាល
៨៣- លោក	ឥណ្ណ	តារា	មន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
៨៤-លោកឧកញ៉ា	គង់	ហោច	សប្បុរសជន
៨៥-លោក	ឌុច	ចាន់	មេឃុំអរិយក្សត្រ
៨៦-លោក	កង	ណាង	មេឃុំ សារិកាកែវ
៨៧-លោក	ស៊ឹម	អាន	មេឃុំ ពាមឧកញ៉ាអុង
៨៨-លោក	ឆង	សំអុល	មេឃុំ ព្រែកឫស្សី
៨៩-លោក	អ៊ូ	សុផាត	មេឃុំ ព្រែកក្អេង
៩០-លោក	រស់	ស៊ុំ	មេឃុំ បារុង
៩១-លោក	ជន	សារឿន	ប្រធានផ្នែកភ័ស្តភាមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៩២-លោក	យង់	សារ៉ាន់	នាយរងការិយាល័យបោះពុម្ពផ្សាយមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៩៣-លោក	គីម	ឡាយ	ប្រធានការិយាល័យហិរញ្ញវត្ថុមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៩៤-លោក	ចាន់	សាន	ប្រធាននាយកដ្ឋានមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
៩៥-លោក	ស៊ុប	គួន	សមាជិកក្រុមប្រឹក្សាឃុំអរិយក្សត្រ
៩៦-លោក	ប៊ុន	សម្បត្តិ	សមាជិកក្រុមប្រឹក្សាឃុំសារិកាកែវ
៩៧-លោក	ជួច	ជឿន	សមាជិកក្រុមប្រឹក្សាឃុំពាមឧកញ៉ាអុង
៩៨-លោក	ឆូ	ណាន	មេឃុំ កោះរះ
៩៩-លោក	សេក	ឡឿច	សមាជិកក្រុមប្រឹក្សាឃុំកោះរះ
១០០-លោក	ឥត	សុខ	មេឃុំ ថ្មគរ
១០១-លោក	ឥត	សាត	សមាជិកក្រុមប្រឹក្សាឃុំថ្មគរ

១០២-លោក	ឡុំ	សំអុន	មេឃុំ ទីកឃ្លាំង
១០៣-លោក	ចាន់	សាន	សមាជិកក្រុមប្រឹក្សាឃុំទីកឃ្លាំង
១០៤-លោក	ឈី	ភូយ	មេឃុំ បឹងគ្រំ
១០៥-លោក	ពៅ	ភែវ	ជំទប់ទី១ ឃុំបឹងគ្រំ
១០៦-លោក	សុខ	សាឡុន	មេឃុំ ល្វាសរ
១០៧-លោកស្រី	ចិន	ហន	ជំទប់ទី១ ឃុំ ល្វាសរ
១០៨-លោកស្រី	ហួន	ម្ទើ	មេឃុំ កោះកែវ
១០៩-លោក	សួន	សាខន	សមាជិកក្រុមប្រឹក្សាឃុំកោះកែវ
១១០-លោក	ម៉ុត	ម៉ុន	សមាជិកក្រុមប្រឹក្សាឃុំកោះកែវ
១១១-លោក	អ៊ី	ហាក់	មេឃុំ សំបូរ
១១២-លោក	ឈិត	ម៉ៃ	ជំទប់ទី១ ឃុំ សំបូរ
១១៣-លោក	ចាន់	សែម	សមាជិកក្រុមប្រឹក្សាឃុំព្រែកឬស្សី
១១៤-លោក	ឌិន	ឌៃច	មេឃុំ ភូមិធំ
១១៥-លោក	ឯម	គីម	មេឃុំ ព្រែករៃ
១១៦-លោក	ឃ្លោក	ឡ្រីច	សមាជិកក្រុមប្រឹក្សាឃុំព្រែករៃ
១១៧-លោក	គង់	ពាច	សមាជិកក្រុមប្រឹក្សាឃុំបារុង
១១៨-លោក	នៅ	ស្យើន	មន្ត្រីសុខាភិបាលស្រុក
១១៩-លោក	សេច	ឃ្យៀន	ប្រធាននាយកដ្ឋាន ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
១២០-លោក	ឌ៉ាត	ឌុត្តា	ប្រធានការិយាល័យក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច
១២១-លោក	សួន	សេដ្ឋា	អនុប្រធានផ្នែក ការិយាល័យមន្ទីរពេទ្យព្រះកេតុមាលា
១២២-លោក	ចាន់	សុវណ្ណុឌី	អនុប្រធានផ្នែក មន្ទីរពេទ្យព្រះកុសមៈ
១២៣-លោក	នច	បេឡាសម្បត្តិ	អនុប្រធានការិយាល័យក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
១២៤-លោក	ឲួន	ឧី	មន្ត្រីក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
១២៥-លោកស្រី	ភែវ	សារៈ	អនុប្រធានការិយាល័យអប់រំ យុវជន និង កីឡាស្រុកល្វាឯម
១២៦-លោក	សេច	ជន	ប្រធានការិយាល័យសាធារណៈការ និង ដឹកជញ្ជូនស្រុកល្វាឯម
១២៧-លោក	ម៉ុន	ម៉ៅ	មន្ត្រីកងរាជអាវុធហត្ថស្រុកល្វាឯម
១២៨-លោក	សាន	ស៊ុនសុរិយា	ប្រធានការិយាល័យប្រៃសនីយ៍ និង ទូរគមនាគមន៍ស្រុកល្វាឯម
១២៩-លោក	សួន	ឧិឆ្ឋានី	មន្ត្រីកងយោធពលខេមរៈភូមិន្ទនៃតំបន់ប្រតិបត្តិការសឹកខេត្តកណ្តាល

១៣០-លោក	ឆុប	សុធា	ប្រធានស្នាក់ការជលផលស្រុកល្វាឯម
១៣១-លោក	ឆិត	ឃីន	អនុប្រធានការិយាល័យកសិកម្មស្រុកល្វាឯម
១៣២-លោក	ជួន	តារាពន្ធ្យ	អនុប្រធានការិយាល័យហិរញ្ញវត្ថុស្រុកល្វាឯម
១៣៣-លោក	ឆ្លាច	សំអុន	អនុប្រធានការិយាល័យបរិស្ថានស្រុកល្វាឯម
១៣៤-លោក	ឃី	សុខ	ប្រធានការិយាល័យហិរញ្ញវត្ថុស្រុកល្វាឯម
១៣៥-លោក	អ៊ីវ	ចួន	ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកល្វាឯម
១៣៦-លោក	សួស	លន់	ប្រធានការិយាល័យធម្មការ និង សាសនាស្រុកល្វាឯម
១៣៧-លោក	ឈាន	ម៉ាន់ណារី	អនុប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់និងភូមិបាល
១៣៨-លោក	ខ្លូត	សំអ៊ឿន	ប្រធានភូមិអរិយក្សត្រ ឃុំ អរិយក្សត្រ
១៣៩-លោក	សៅ	សាខាំ	ប្រធានភូមិខ្សាច់ ឃុំ អរិយក្សត្រ
១៤០-លោក	ប៊ុន	ឃន់	ប្រធានភូមិពោធិធំ ឃុំ អរិយក្សត្រ
១៤១-លោក	ឆួន	ឆឿន	ប្រធានភូមិទួលមាស ឃុំ អរិយក្សត្រ
១៤២-លោក	ហោច	ស៊ាចឆ៊ី	ជំទប់ទី១ ឃុំសារិកាកែវ
១៤៣-លោក	អាន	សំបូរ	ប្រធានភូមិក្តីកណ្តាល ឃុំ សារិកាកែវ
១៤៤-លោក	ហាច្ន	ម៉ឿន	ប្រធានភូមិតាជោ ឃុំ សារិកាកែវ
១៤៥-លោក	ឌឹម	ជួន	ប្រធានភូមិតាស្គរ ឃុំសារិកាកែវ
១៤៦-លោក	ញ៉ឹម	ជាន	ប្រធានភូមិព្រែកតាអុងទី១ ឃុំ ពាមឧកញ៉ាអុង
១៤៧-លោក	សុខ	ចូរី	ប្រធានភូមិពាមតាឯក ឃុំ ពាមឧកញ៉ាអុង
១៤៨-លោក	ឆ័ន	ហ្វ	ប្រធានភូមិព្រែកតាអុងទី២ ឃុំ ពាមឧកញ៉ាអុង
១៤៩-លោក	ឃន	ធា	អនុប្រធានភូមិព្រែកតាអុងទី២ ឃុំ ពាមឧកញ៉ាអុង
១៥០-លោក	គុជ	កែវ	មេភូមិព្រែកតាអុងទី៣ ឃុំពាមឧកញ៉ាអុង
១៥១-លោក	ជា	រិន	ប្រធានភូមិវាលធំ ឃុំ ពាមឧកញ៉ាអុង
១៥២-លោក	សុំន	ឈៀប	សមាជិកក្រុមប្រឹក្សាឃុំពាមឧកញ៉ាអុង
១៥៣-លោក	ភន	សុខភាយ	ស្មៀនឃុំពាមឧកញ៉ាអុង
១៥៤-លោក	ឃង់	ឈួន	សមាជិកក្រុមប្រឹក្សាឃុំពាមឧកញ៉ាអុង
១៥៥-លោក	ឆង់	សារុន	ប្រធានភូមិ កោះរះលើ ឃុំ កោះរះ
១៥៦-លោក	ឆៅ	យ៉ែម	សមាជិកក្រុមប្រឹក្សាឃុំកោះរះ
១៥៧-លោក	ជា	សុផល	ជំទប់ទី១ឃុំកោះរះ

១៥៨-លោក	សំ	ស្បឿន	ប្រធានភូមិ ផ្លូវត្រើ ឃុំ ថ្មគរ
១៥៩-លោក	នៅ	គង់	ប្រធានភូមិ ថ្មគរ ឃុំ ថ្មគរ
១៦០-លោកស្រី	កង	សារី	ក្រុមប្រឹក្សាឃុំថ្មគរ
១៦១-លោក	ម៉ម	ជាន	មេភូមិទឹកឃ្លាំង ឃុំ ទឹកឃ្លាំង
១៦២-លោក	អោម	ឃួន	មេភូមិសំរោង ឃុំ ទឹកឃ្លាំង
១៦៣-លោក	អ៊ុម	ធន	ប្រធានភូមិជ្រោយពិសី ឃុំ ទឹកឃ្លាំង
១៦៤-លោក	សាយ	ហួរ	ក្រុមប្រឹក្សាឃុំទឹកឃ្លាំង
១៦៥-លោក	នាង	សុីផូ	សមាជិកក្រុមប្រឹក្សាឃុំចឹងគ្រំ
១៦៦-លោក	សុខ	ហ៊ីន	ប្រធានភូមិចឹងគ្រំលើ ឃុំ ចឹងគ្រំ
១៦៧-លោក	ឡាំ	ជាន	ប្រធានភូមិចឹងគ្រំក្រោម ឃុំ ចឹងគ្រំ
១៦៨-លោក	ឡឺក	ឡោ	ក្រុមប្រឹក្សាឃុំល្វាសរ
១៦៩-លោក	យឹម	ថន	ប្រធានភូមិល្វាសរលើ ឃុំ ល្វាសរ
១៧០-លោក	ប៊ុស	ណាន	ប្រធានភូមិល្វាសរកណ្តាល ឃុំ ល្វាសរ
១៧១-លោក	ចឺត	ជុំ	ប្រធានភូមិល្វាសរក្រោម ឃុំ ល្វាសរ
១៧២-លោក	មាស	ស្បឿន	សមាជិកក្រុមប្រឹក្សាឃុំកោះកែវ
១៧៣-លោកស្រី	ខាន់	សារុន	ប្រធានភូមិកោះកែវលើ ឃុំ កោះកែវ
១៧៤-លោកស្រី	ជា	សុីណា	ប្រធានភូមិកោះកែវក្រោម ឃុំ កោះកែវ
១៧៥-លោក	សេង	ឈន	សមាជិកក្រុមប្រឹក្សាឃុំ ឃុំសំបួរ
១៧៦-លោក	ថុល	ជាន់	ប្រធានភូមិសំបួរ ឃុំ សំបួរ
១៧៧-លោក	ហ៊ុន	ហាន	ប្រធានភូមិព្រែកចារ ឃុំ សំបួរ
១៧៨-លោក	ឆួយ	សុីវន	ប្រធានភូមិជ្រោយជ្រៃ ឃុំ សំបួរ
១៧៩-លោក	ជួប	ប៊ុត	ប្រធានភូមិ ព្រែកប្រា ឃុំ ព្រែកឫស្សី
១៨០-លោក	ហាន	គង់	ប្រធានភូមិព្រែកជ្រៃ ឃុំ ព្រែកឫស្សី
១៨១-លោក	ខ្វាន់	សម្បត្តិ	ប្រធានភូមិ ព្រែកឫស្សី ឃុំ ព្រែកឫស្សី
១៨២-លោក	យ៉ឹម	យាន	ប្រធានភូមិ អន្លង់ទ្រា ឃុំ ព្រែកឫស្សី
១៨៣-លោក	សៅ	សុវណ្ណ	ប្រធានភូមិពាមស្តី ឃុំ ព្រែកឫស្សី
១៨៤-លោក	ឆួ	សម្បត្តិ	ក្រុមប្រឹក្សាឃុំព្រែកឫស្សី
១៨៥-លោក	ហៀង	ឆួ	ប្រធានភូមិព្រែកតាប្រាំង ឃុំ ភូមិធំ

១៨៦-លោក	ឧេព	ចែម	ប្រធានភូមិ ព្រែកវែ ឃុំ ព្រែកវែ
១៨៧-លោក	ឧួន	ឡេច	ប្រធានភូមិ ព្រែកឈ្មោះ ឃុំ ព្រែកវែ
១៨៨-លោក	អ៊ូ	ឌុន	ប្រធានភូមិ ព្រែកគង់រាជ ឃុំ ព្រែកវែ
១៨៩-លោក	ភួង	សាត	សមាជិកក្រុមប្រឹក្សាឃុំព្រែកក្មេង
១៩០-លោក	សួន	សំអឿន	ប្រធានភូមិព្រែកក្មេង ឃុំ ព្រែកក្មេង
១៩១-លោក	ពៅ	សុផល	ប្រធានភូមិទួលទ្រា ឃុំ ព្រែកក្មេង
១៩២-លោក	ថោង	ម៉ុត	សមាជិកក្រុមប្រឹក្សាឃុំបារុង
១៩៣-លោក	វង់	សារ៉ែន	ប្រធានភូមិបារុង ឃុំ បារុង
១៩៤-លោក	ឆួន	ចក់	ប្រធានភូមិ ខ្នោរការ ឃុំ បារុង
១៩៥-លោក	ចាន់	ចេង	សមាជិកក្រុមប្រឹក្សាឃុំអរិយក្សត្រ
១៩៦-លោកស្រី	ឆាន	យ៉ង់	សមាជិកក្រុមប្រឹក្សាឃុំអរិយក្សត្រ
១៩៧-លោក	អ៊ុយ	សំអុល	ប្រធានភូមិព្រែកក្រួច ឃុំ ភូមិធំ
១៩៨-លោក	ឆឺ	កីមហេង	ប្រធានការិយាល័យ ក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
១៩៩-លោក	អឿម	ប៊ុណ្ណា	មន្ត្រីក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
២០០-លោកស្រី	ឌី	ឆុចធី	ប្រធានការិយាល័យ ក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
២០១-លោកស្រី	ខ្វៃ	ឈី	មន្ត្រីក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
២០២-លោក	ង៉ាត់	ការិត	ប្រធាននាយកដ្ឋានស្រាវជ្រាវ អភិវឌ្ឍន៍មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២០៣-លោក	អ៊ីវ	ថន	នាយផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាលមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២០៤-លោក	ប៉ូល	ណារឿន	មន្ត្រីអភិវឌ្ឍន៍មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២០៥-លោក	សេក	ចារិន្ទ	នាយផ្នែកបច្ចេកទេសរាយមីនមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២០៦-លោក	ឆុន	យ៉ន្ត	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២០៧-លោក	គីម	សារ៉ាឆុន	បសុពេទ្យប្រចាំស្រុកល្វាឯម
២០៨-លោក	ង៉ូច	ចូរ៉ា	មន្ត្រីក្រសួងសុខាភិបាល
២០៩-លោក	ឈី	ហុច	អនុប្រធានការិ.អភិវឌ្ឍន៍ជនបទស្រុកល្វាឯម
២១០-លោក	ស្រ៊ី	រិទ្ធីសំភ្ព	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២១១-លោក	តៅ	ប៊ុនឆឿន	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២១២-លោក	ចួច	ហ៊ូ	មន្ត្រីនាយកដ្ឋានស្រាវជ្រាវ ចារនិច្ច
២១៣-លោក	វ័ណ្ឌ	សារ៉ុម	មន្ត្រីជំនួយការ លោកអភិបាលស្រុកល្វាឯម

២១៤-លោក	យស់	ស្រ៊ឿច	មន្ត្រីនាយកដ្ឋានស្រាវជ្រាវ ចារនិច្ច
២១៥-លោកស្រី	សន	រី	មន្ត្រីសាលាស្រុកល្វាឯម
២១៦-លោកស្រី	អាច	សំអាត	មន្ត្រីសាលាស្រុកល្វាឯម
២១៧-លោក	រស់	ទ៉ាន់ថន	ប្រធានមណ្ឌលសុខភាពអរិយក្សត្រ
២១៨-លោក	ជាំ	ស៊ុំណាន់	មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកល្វាឯម
២១៩-លោក	ឆួ	សារ៊ុម	អធិការរងនគរបាលស្រុកល្វាឯម
២២០-លោក	យស់	ទ៉ាន់ឌី	អធិការរងនគរបាលស្រុកល្វាឯម
២២១-លោក	រស់	សារីម	អនុប្រធានភូមិខ្សាច់ ឃុំ អរិយក្សត្រ
២២២-លោក	ឈួន	ថៃ	អនុប្រធានភូមិខ្សាច់ ឃុំ អរិយក្សត្រ
២២៣-លោក	សាន	ចាន់នី	អនុប្រធានភូមិពោធិធំ ឃុំ អរិយក្សត្រ
២២៤-លោក	ពត	ណូ	អនុប្រធានភូមិទួលមាស ឃុំ អរិយក្សត្រ
២២៥-លោក	មែ	សំណាង	សមាជិកក្រុមប្រឹក្សាឃុំសារិកាកែវ
២២៦-លោក	ជុំន	ញ៉ែ	អនុប្រធានភូមិតាស្គរ ឃុំ សារិកាកែវ
២២៧-លោក	ជន	ជូ	អនុប្រធានភូមិព្រែកតាអុងទី១ ឃុំ ពាមឧកញ៉ាអុង
២២៨-លោក	ប៊ូ	សុត	អនុប្រធានភូមិពាមតាឯក ឃុំ ពាមឧកញ៉ាអុង
២២៩-លោក	សន	ខុន	អនុប្រធានភូមិព្រែកតាអុងទី៣ ឃុំ ពាមឧកញ៉ាអុង
២៣០-លោក	ខាត់	ខែម	អនុប្រធានភូមិវាលធំ ឃុំ ពាមឧកញ៉ាអុង
២៣១-លោក	សាយ	ឡាយ	អនុប្រធានភូមិកោះរះលើ ឃុំ កោះរះ
២៣២-លោក	ម៉ៅ	ម៉្រឹន	អនុប្រធានភូមិកោះរះក្រោម ឃុំ កោះរះ
២៣៣-លោក	សុំន	ឯម	អនុប្រធានភូមិផ្លូវត្រី ឃុំ ថ្មគរ
២៣៤-លោកស្រី	កែវ	ស៊ុំណន	អនុប្រធានភូមិថ្មគរ ឃុំ ថ្មគរ
២៣៥-លោក	សុក	ខុន	អនុប្រធានភូមិទឹកឃ្លាំង ឃុំ ទឹកឃ្លាំង
២៣៦-លោកស្រី	ឆួ	សារុន	អនុប្រធានភូមិសំរោង ឃុំ ទឹកឃ្លាំង
២៣៧-លោក	សរ	ឡុច	អនុប្រធានភូមិជ្រោយពិសី ឃុំ ទឹកឃ្លាំង
២៣៨-លោក	សុខ	តាំង	អនុប្រធានភូមិបឹងគ្រំលើ ឃុំ បឹងគ្រំ
២៣៩-លោក	ឈឹម	អ៊ឿន	អនុប្រធានភូមិបឹងគ្រំក្រោម ឃុំ បឹងគ្រំ
២៤០-លោក	ឌិច	ភាន	សមាជិកក្រុមប្រឹក្សាឃុំល្វាសរ
២៤១-លោក	អ៊ូ	រិន	សមាជិកក្រុមប្រឹក្សាឃុំល្វាសរ

២៤២-លោក	ហែម	រស់	អនុប្រធានភូមិល្វាសរលើ ឃុំ ល្វាសរ
២៤៣-លោក	ឈី	ឌីត	អនុប្រធានភូមិល្វាសរកណ្តាល ឃុំ ល្វាសរ
២៤៤-លោក	អ៊ិម	សៀក	អនុប្រធានភូមិល្វាសរក្រោម ឃុំ ល្វាសរ
២៤៥-លោក	សោម	ស៊ីត	សមាជិកភូមិកោះរះក្រោម ឃុំ កោះកែវ
២៤៦-លោក	អៀម	មៀម	ជំទប់ទី១ ឃុំកោះកែវ
២៤៧-លោក	សុខ	សាន	អនុប្រធានភូមិកោះកែវក្រោម ឃុំ កោះកែវ
២៤៨-លោក	យា	គីមសាន	អនុប្រធានភូមិសំបូរ ឃុំ សំបូរ
២៤៩-លោកស្រី	ម៉ាក់	ខូម	អនុប្រធានភូមិព្រែកចារ ឃុំ សំបូរ
២៥០-លោក	ឃុត	ម៉ុន	អនុប្រធានភូមិជ្រោយជ្រៃ ឃុំ សំបូរ
២៥១-លោក	ឆេង	ឆុន	អនុប្រធានភូមិព្រែកប្រា ឃុំ ព្រែកឬស្សី
២៥២-លោក	សុខ	ឌួន	អនុប្រធានភូមិព្រែកជ្រៃ ឃុំ ព្រែកឬស្សី
២៥៣-លោក	ស៊ីង	ហេង	អនុប្រធានភូមិព្រែកឬស្សី ឃុំ ព្រែកឬស្សី
២៥៤-លោក	មើង	សាត	អនុប្រធានភូមិអន្ទុងទ្រា ឃុំ ព្រែកឬស្សី
២៥៥-លោក	សុខ	ន៊ី	អនុប្រធានភូមិពាមស្តី ឃុំ ព្រែកឬស្សី
២៥៦-លោក	ឌិន	ឆេងលី	ប្រធានភូមិព្រែកតាប្រាំង ឃុំ ភូមិធំ
២៥៧-លោក	ន៊ី	ផេង	អនុប្រធានភូមិព្រែកតាប្រាំង ឃុំ ភូមិធំ
២៥៨-លោក	សំ	ម៉ុល	សមាជិកក្រុមប្រឹក្សាឃុំភូមិធំ
២៥៩-លោក	អ៊ូ	សំបូរ	សមាជិកក្រុមប្រឹក្សាឃុំភូមិធំ
២៦០-លោក	ឌា	ថារ៉ាត	អនុប្រធានភូមិព្រែកតាប្រាំង ឃុំ ភូមិធំ
២៦១-លោក	ផាង	ឌ្យុក	អនុប្រធានភូមិព្រែកក្រូច ឃុំ ភូមិធំ
២៦២-លោក	នង	នាង	អនុប្រធានភូមិព្រែករៃ ឃុំ ព្រែករៃ
២៦៣-លោក	ឡាក់	ឧត្ម	ជំនួយការភូមិព្រែកឈ្មោះ ឃុំ ព្រែករៃ
២៦៤-លោក	ហ៊ុយ	លាង	អនុប្រធានភូមិព្រែកគង់រាជ ឃុំ ព្រែករៃ
២៦៥-លោក	នៅ	ញ្រើង	អនុប្រធានភូមិព្រែកក្មេង ឃុំ ព្រែកក្មេង
២៦៦-លោក	ឯម	ឧត្តា	អនុប្រធានភូមិទូលទ្រា ឃុំ ព្រែកក្មេង
២៦៧-លោក	ឯម	អាត	អនុប្រធានភូមិបារុង ឃុំ បារុង
២៦៨-លោក	ហែម	ហុង	អនុប្រធានភូមិខ្នោរការ ឃុំ បារុង
២៦៩-លោក	ឌ៉ង់	គីមហួន	អនុប្រធានភូមិកោះកែវលើ ឃុំ កោះកែវ

២៧០-លោក	សេង	ពិសិដ្ឋ	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧១-លោក	ហួត	សុវណ្ណារិទ្ធិ	មន្ត្រីក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និង អធិការកិច្ច
២៧២-លោក	អ៊ុច	ជំនោរ	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧៣-លោក	កែវ	នេត្រា	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧៤-លោក	សៀន	ភុជចាន់ណាវី	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧៥-លោក	ឌុល	សារ៉ុន	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧៦-លោក	នេត	រដ្ឋា	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧៧-លោក	សូ	ឥណ្ណី	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧៨-លោក	គុណ	សិលា	មន្ត្រី មជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា
២៧៩-លោក	ជា	អូន	អនុភូមិអរិយក្សត្រ ឃុំ អរិយក្សត្រ
២៨០-លោកស្រី	សោម	សុខុម	ជំនួយការអរិយក្សត្រ ឃុំ អរិយក្សត្រ
២៨១-លោកស្រី	នៅ	សារ៉ុន	ជំនួយការភូមិខ្សាច់ ឃុំ អរិយក្សត្រ
២៨២-លោកស្រី	ចាប	សេងលី	ជំនួយការភូមិពោធិ៍ ឃុំ អរិយក្សត្រ
២៨៣-លោកស្រី	សំ	សុតី	ជំនួយការភូមិទួលមាស ឃុំ អរិយក្សត្រ
២៨៤-លោកស្រី	អ៊ុត	ចាន់ថា	សមាជិកភូមិតាជោ ឃុំ សារិកាកែវ
២៨៥-លោកស្រី	ម៉ន	ឡួន	សមាជិកភូមិក្តីកណ្តាល ឃុំ សារិកាកែវ
២៨៦-លោកស្រី	ឡុយ	សម្បត្តិ	សមាជិកភូមិតាស្គរ ឃុំ សារិកាកែវ
២៨៧-លោកស្រី	សោម	ស្រេង	សមាជិកភូមិព្រែកតាអុងទី១ ឃុំ ពាមឧកញ៉ាអុង
២៨៨-លោកស្រី	ឯម	ចិនលី	សមាជិកភូមិពាមតាឯក ឃុំ ពាមឧកញ៉ាអុង
២៨៩-លោកស្រី	សយ	ឃុំម	សមាជិកភូមិព្រែកតាអុងទី ២ ឃុំ ពាមឧកញ៉ាអុង
២៩០-លោកស្រី	ឃីម	សុខែម	សមាជិកភូមិព្រែកតាអុងទី ៣ ឃុំ ពាមឧកញ៉ាអុង
២៩១-លោកស្រី	ចុិច	ថន	សមាជិកភូមិវាលធំ ឃុំ ពាមឧកញ៉ាអុង
២៩២-លោកស្រី	ជួប	នាង	ជំនួយការភូមិកោះរះលើ ឃុំ កោះរះ
២៩៣-លោកស្រី	ឃីម	សាយ	ជំនួយការភូមិកោះរះក្រោម ឃុំ កោះរះ
២៩៤-លោកស្រី	ឃូ	រស់	ជំនួយការភូមិផ្លូវត្រី ឃុំ ថ្មគរ
២៩៥-លោក	ពត	គីមថុន	ជំនួយការភូមិថ្មគរ ឃុំ ថ្មគរ
២៩៦-លោកស្រី	សោម	សុភាព	ជំនួយការភូមិទឹកឃ្លាំង ឃុំ ទឹកឃ្លាំង
២៩៧-លោក	រស់	ឃុន	ជំនួយការភូមិ សំរោង ឃុំ ទឹកឃ្លាំង

២៩៨-លោកស្រី	សាំង	សាវ៉ែ	ជំនួយការភូមិជ្រោយពិសី ឃុំ ទឹកឃ្លាំង
២៩៩-លោកស្រី	ឆាង	សុផាន្នី	ជំនួយការភូមិបឹងត្រំលើ ឃុំ បឹងត្រំ
៣០០-លោកស្រី	ហែម	សាយ	ជំនួយការភូមិបឹងត្រំក្រោម ឃុំ បឹងត្រំ
៣០១-លោកស្រី	ប៊ូ	ស្បឿន	សមាជិកភូមិល្វាសរលើ ឃុំ ល្វាសរ
៣០២-លោកស្រី	ភង	ឆួច	សមាជិកភូមិល្វាសរកណ្តាល ឃុំ ល្វាសរ
៣០៣-លោក	អ៊ុន	សុតាព	សមាជិកភូមិល្វាសរកណ្តាល ឃុំ ល្វាសរ
៣០៤-លោក	សែត	ថៃ	សមាជិកភូមិកោះកែវលើ ឃុំ កោះកែវ
៣០៥-លោក	ហ៊ិន	ហាន	សមាជិកភូមិកោះកែវក្រោម ឃុំ កោះកែវ
៣០៦-លោកស្រី	ឆន	សាឆុន	ជំនួយការភូមិសំបួរ ឃុំ សំបួរ
៣០៧-លោក	រិក	ម៉ៃ	ជំនួយការភូមិព្រែកចារ ឃុំ សំបួរ
៣០៨-លោកស្រី	ប៊ុត	សុខា	ជំនួយការភូមិជ្រោយជ្រៃ ឃុំ សំបួរ
៣០៩-លោកស្រី	ជួប	យ៉ឿង	ជំនួយការភូមិព្រែកប្រា ឃុំ ព្រែកឫស្សី
៣១០-លោកស្រី	សេង	សាម៉ៃ	ជំនួយការភូមិព្រែកជ្រៃ ឃុំ ព្រែកឫស្សី
៣១១-លោកស្រី	សុខ	យ៉ាន	ជំនួយការភូមិព្រែកឫស្សី ឃុំ ព្រែកឫស្សី
៣១២-លោកស្រី	ឈឺន	អួន	ជំនួយការភូមិអន្លង់ទ្រា ឃុំ ព្រែកឫស្សី
៣១៣-លោកស្រី	ឆង	សំអាត	ជំនួយការភូមិពាមស្តី ឃុំ ព្រែកឫស្សី
៣១៤-លោកស្រី	ឆង	ថេង	ជំនួយការភូមិព្រែកតាប្រាំង ឃុំ ព្រែកឫស្សី
៣១៥-លោកស្រី	ចិន	យ៉ៅត	ជំនួយការភូមិព្រែកក្រូច ឃុំភូមិធំ
៣១៦-លោកស្រី	ជុំ	សំបូរ	ជំនួយការភូមិព្រែករៃ ឃុំ ព្រែករៃ
៣១៧-លោកស្រី	សុិន	អ៊ឿន	ជំនួយការភូមិព្រែកឈ្នោះ ឃុំ ព្រែករៃ
៣១៨-លោកស្រី	គៀត	ណន	ជំនួយការភូមិព្រែកគង់រាជ ឃុំ ព្រែករៃ
៣១៩-លោកស្រី	ជា	សំអ៊ឿន	ជំនួយការភូមិព្រែកក្អែង ឃុំ ព្រែកក្អែង
៣២០-លោកស្រី	ឃុច	ឈេត	ជំនួយការភូមិទួលទ្រា ឃុំ ព្រែកក្អែង
៣២១-លោកស្រី	ឡៀម	សុផល	សមាជិកភូមិបារុង ឃុំ បារុង
៣២២-លោកស្រី	អ៊ុំ	ថៃ	សមាជិកភូមិខ្នោការ ឃុំ បារុង
៣២៣-លោកស្រី	ឆុត	សុីឡឿន	មន្ត្រីអធិការដ្ឋាននគរបាលស្រុកល្វាឯម
៣២៤-លោក	សំ	ចន	សមាជិកក្រុមប្រឹក្សាឃុំគរគីធំ
៣២៥-លោក	គង់	គីមជួន	មន្ត្រីមជ្ឈមណ្ឌលជាតិកំចាត់មីននៃកម្ពុជា

៣២៦-លោក	ឆើម	សេរីវឌ្ឍន៍	មន្ត្រីសាលាខេត្តកណ្តាល
៣២៧-លោក	ជា	សុរក្សា	មន្ត្រីសាលាខេត្តកណ្តាល
៣២៨-លោក	ឈារ៉ា	ចំរើន	មន្ត្រីសាលាខេត្តកណ្តាល
៣២៩-លោក	អ៊ូ	ចាន់ឆ្ល	មន្ត្រីនគរបាលជាតិក្រសួងមហាផ្ទៃ
៣៣០-លោក	អ៊ូ	ខាសនា	មន្ត្រីនគរបាលជាតិក្រសួងមហាផ្ទៃ
៣៣១-លោក	អ៊ុយ	សំណាង	មន្ត្រីនគរបាលជាតិក្រសួងមហាផ្ទៃ
៣៣២-លោក	ង្វាង	សំអាន	មន្ត្រីនគរបាលជាតិក្រសួងមហាផ្ទៃ
៣៣៣-លោក	ខៀវ	សុខចន្ទំសុធា	មន្ត្រីនគរបាលជាតិក្រសួងមហាផ្ទៃ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

គន្លងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១ និងមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៧.៣.៣.៣...អនក្រ.តង

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្ទាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

សម្រេច

មាត្រា ១ : តែងតាំងលោក **នុត សេដ្ឋា** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការ នៃក្រសួងផែនការ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩

ទីស្នាក់ការដ្ឋមន្ត្រី

ទីស្នាក់ការដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦៣៤ . រាជក្រ.៩៩

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ចំនួន ៦៧ រូប ដែលមានស្នាដៃល្អ ក្នុងការរួមសហការជាមួយដៃគូ អង្គការជាតិ អន្តរជាតិ លើការងារពិការភាព និង ការស្តារកាយសម្បទា ការអភិវឌ្ឍន៍ផ្សេងៗ ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសការងារ :

១.លោកស្រី **នូ ឫទហ៊ុន**	ប្រធានការិយាល័យសេវាស្តារលទ្ធភាពពលកម្មតាមសហគមន៍
